# កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ
# ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រជាជនស៊ុយអែត

United Nations Development Programme
Swedish International Development Agency

# គំរោងអភិវឌ្ឍន៍ និងស្តារឡើងវិញនៃតំបន់ជនបទ
# ប្រទេសកម្ពុជា (ឃែរេរេ_សិលា)

# CAMBODIA AREA REHABILITATION AND REGENERATION PROJECT (CARERE/SEILA) CMB/95/011

# របាយការណ៍ របស់ក្រុមបេសកកម្មវាយតំលៃ
# ជាយុទ្ធសាស្ត្រលើកម្មវិធី សិលា

ខែ មិនា ឆ្នាំ ២០០០

# Report of the Joint Evaluation Mission

March 2000

Hugh Evans (Team Leader)
Lars Birgegaard
Peter Cox
Lim Siv Hong

library.ncdd.gov.kh
008245

## ក. សេចក្តីផ្តើម

របាយការណ៍នេះត្រូវបានរៀបចំឡើងនៅក្នុងខែ មិនា ឆ្នាំ ២០០០ ដោយសមាជិកនៃក្រុមបេសកកម្មមួយ ដែលបានចាត់តាំងឡើង ដើម្បីធ្វើការវាយតំលៃជាយុទ្ធសាស្រ្តទៅលើកម្មវិធី ឃែរេរេ ២ - សិលា (ដែលពីពេលនេះតទៅ យើងនិងហៅដោយខ្លីថាជា កម្មវិធីសិលា)។ លក្ខន្តិកៈការងាររបស់ក្រុមវាយតំលៃយើងគឺ : ធ្វើការវាយតំលៃទៅលើ ទំនាក់ទំនង ប្រសិទ្ធភាព និរន្តរភាព និងភាពដែលអាចចំលងតាមបានរបស់កម្មវិធីសិលា ក្នុងបរិបទនៃការអភិវឌ្ឍន៍ តាមបែបវិមជ្ឈការ ដោយផ្តោតជាពិសេសទៅលើភាពពាក់ពន្ធ័សំរាប់កម្មវិធីនាពេលអនាគត ។

សូមបញ្ជាក់ថា របាយការណ៍នេះគឺមិនមែនជាការវាយតំលៃបញ្ចប់កម្មវិធី ហើយក៏មិនមែនជាការរៀបចំបង្កើតនៃកម្មវិធីនាពេលអនាគតនោះដែរ ។

ក្រុមបេសកកម្មបានចំណាយពេល បួនសប្តាហ៍នៅក្នុងប្រទេសកម្ពុជា គឺបីសប្តាហ៍នៅទីក្រុងភ្នំពេញ និងមួយសប្តាហ៍ទៅតាមខេត្ត ដែលជាកន្លែងមានប្រតិបត្តិការកម្មវិធីនេះ ។ នៅទីក្រុងភ្នំពេញយើងបានរៀបចំការប្រជុំជាច្រើនលើកជាមួយ និងអ្នកផ្តល់ជំនួយ ភ្នាក់ងាររដ្ឋាភិបាល និងអ្នកផ្សេងៗទៀតដែលមានការពាក់ពន្ធ័ជាមួយនិងកម្មវិធីសិលានេះ ។ នៅតាមខេត្ត យើងបានចំណាយពេលពី ពីរទៅបីថ្ងៃសំរាប់ខេត្តនិមួយៗ គឺមានខេត្តពោធិសាត់ ខេត្តបាត់ដំបង និងខេត្តសៀមរាប ហើយយើងក៏បានចំនាយពេលមួយភ្លែតដែរនៅការិយាល័យឃែរេរេខេត្តបន្ទាយមានជ័យ ។ នៅក្នុងខេត្តនិមួយៗនោះ យើងបានមានឱកាសដើម្បីជួបប្រជុំជាមួយនិងសមាជិកនៃ គណៈកម្មាធិការប្រតិបត្តិព្រមទាំងសមាជិកនៃផ្នែកសំខាន់ៗរបស់គណៈកម្មាធិការនេះ បានជួបប្រជុំជាមួយគណៈកម្មការអភិវឌ្ឍន៍ឃុំជាច្រើន និងបានជួបប្រជុំជាមួយបុគ្គលិក ក្រុមពង្រឹងសមត្ថភាពមូលដ្ឋានរបស់ឃែរេរេ ផងដែរ ។

## ខ. ការពិពណ៌នាទូទៅខ្លីៗ

### ១. តើសិលាគឺជាអ្វី ?

ភាពពិបាកខ្លះៗចំពោះអ្នកអង្កេតការមួយចំនួន ដែលជារឿយៗបានយល់ឃើញក្នុងការកំណត់កម្មវិធីសិលាថា កម្មវិធីសិលាបានមានដំណើរការយ៉ាងរឹងមាំមួយដែលធ្វើការផ្លាស់ប្តូរនូវការផ្តោត និងបរិបទរបស់ខ្លួនជាប្រចាំ ។ ផ្តើមចេញពីការងារផ្តល់ជំនួយដ៏ធំមួយ ដែលជាយថាហេតុត្រូវបានហៅថា សិលា បែរបន្តិចម្តងៗទៅជាការងារអភិវឌ្ឍន៍ តាមបែបធ្វើការពិសោធន៍ នៅក្នុងឆ្នាំ ១៩៩៦- ១៩៩៧ ។ ការវិវត្តន៍នៃវិធីសាស្រ្តសំរាប់ការធ្វើផែនការតាមបែបវិមជ្ឈការ គឺជាការងារចំបងរបស់កម្មវិធី ដែលបានបន្ត និងធ្វើការផ្លាស់ប្តូរជាប្រចាំនូវមាតិកា និងយុទ្ធសាស្រ្ត ។ សេចក្តីត្រូវការដើម្បីឆ្លើយតបទៅនិងការប្រឹងប្រែងធ្វើសមាហរណកម្ម

ក្នុងតំបន់អតីតខ្មែរក្រហម បាននាំអោយមានការកែប្រែនូវគោលបំណងរបស់សិលា ព្រមទាំងតំបន់គោលដៅផងដែរ ។ នេះគឺជាចំណុចដែលធ្វើអោយផ្លាស់ប្តូរសិលា ។

បច្ចុប្បន្នសិលាមានរូបរាងពេញលេញនៅក្នុងស្ថានភាពមួយដែលអាចត្រូវបានពិពណ៌នា ឬកំណត់តាមវិធីដូចខាងក្រោមនេះ :

សិលាគឺជាគោលគំនិត ( ទស្សនទាន )សំរាប់ការធ្វើផែនការ និងអភិវឌ្ឍន៍នៅថ្នាក់មូលដ្ឋាន និងតំបន់ ។ គោលគំនិតនេះ ត្រូវបានរកឃើញនៅក្នុងគោលការណ៍មួយចំនួន ។ គោលការណ៍ទាំងនេះវាទាក់ទងទៅនិងការផ្តល់សិទ្ធិអំណាច ការចូលរួម តម្លាភាព និងគណនេយ្យភាព ។ នៅក្នុងឯកសារគោលនយោបាយសិលា គោលការណ៍ទាំងនេះត្រូវបានបរិយាយយ៉ាងល្អិតល្អន់នៅក្នុងពាក្យចំនួនបួន គឺ : ការពិភាក្សា ការបញ្ជាក់ច្បាស់លាស់ ការព្រមព្រៀង និងការគោរព ។

ដើម្បីបញ្ជាក់ទៅលើគោលការណ៍ទាំងនេះ ក្នុងគោលគំនិតសិលាសំរាប់ការអភិវឌ្ឍន៍ និងការធ្វើផែនការមូលដ្ឋាននិង តំបន់បានមានបង្កើតនូវគោលបំណងមួយឈុត ព្រមទាំងមានការកំណត់នៃតួនាទី និងទំនាក់ទំនងរវាងអ្នកអភិវឌ្ឍន៍ ជាមួយនិងវិធីសាស្រ្ត បច្ចេកទេស ឧបករណ៍ បែបបទរដ្ឋបាល និង របៀបគំរូនៃការគ្រប់គ្រង ។ លក្ខណៈសំខាន់របស់គោលគំនិតសិលានេះគឺ ទំហំវិសាលភាពរបស់វា ។ កម្មវិធីនេះវាមានរួមបញ្ចូលទាំងស្ថាប័នសង្គមស៊ីវិលនៅថ្នាក់មូលដ្ឋាន ( គណៈកម្មការអភិវឌ្ឍន៍ភូមិ ឃុំ ក្រុមអ្នកប្រើប្រាស់សេវារួម អង្គការក្រៅរដ្ឋាភិបាល ។ល។ ) ព្រមទាំងស្ថាប័នថ្នាក់ស្រុក និងខេត្តជាច្រើនទៀត ។

ដូច្នេះលក្ខណៈពិសេសតែមួយគត់របស់កម្មវិធីសិលាគឺ ការចង់សង្កត់ធ្ងន់ទៅលើប្រពន្ធ័នៃការអភិវឌ្ឍន៍មូលដ្ឋាន និង តំបន់ទាំងមូល ។

កម្មវិធីសិលា ក៏ជាកម្មវិធីប្រតិបត្តិការមួយដែរ ។ ដូចជា កម្មវិធីសិលានេះបានបន្តិរកនូវភាពសំរបសំរួលនិងកែលំអរនូវគោលគំនិតរបស់ខ្លួន ដែលបានកំពុងដាក់អោយដំណើរការនៅក្នុងខេត្តទាំងប្រាំ ។ វាមិនត្រឹមតែបានធ្វើការពិភាក្សាដោយយកចិត្តទុកដាក់ចំពោះយុទ្ធវិធីក្នុងការអភិវឌ្ឍន៍ និង ភស្តុតាងដែលគួរអោយទុកចិត្តបាន ព្រមទាំងសក្តានុពលរបស់ខ្លួនប៉ុណ្ណោះទេ ថែមទាំងយកចិត្តទុកដាក់ទៅលើមធ្យោបាយដែលនាំអោយកម្មវិធិសិលាអាចលទ្ធភាពធ្វើអោយបានសំរេចនូវគោលដៅអភិវឌ្ឍន៍របស់ខ្លួនទៀតផង ។

## ២. <u>សមិទ្ធិផលដែលសំរេចបាន</u>

តាមរយៈការវាយតំលៃជាច្រើន ដូចជា ការវាយតំលៃពាក់កណ្តាលកម្មវិធី ការវាយតំលៃរបស់សហគមន៍អ៊ឺរ៉ុប ទៅលើការគាំទ្ររបស់គេ ការវាយតំលៃនៃមូលនិធិអភិវឌ្ឍន៍មូលដ្ឋាន និងការវាយ តំលៃផ្ទៃក្នុង ព្រមទាំងការ

អង្កេតក្រៅផ្លូវការ (ការអង្កេតដោយក្រុមទីប្រឹក្សា របស់ភ្នាក់ងារអភិវឌ្ឍន៍ អន្តរជាតិនៃប្រជាជនស៊ុយអ៊ែត ) សុទ្ធតែបានផ្តល់យោបល់អោយឃើញថា កម្មវិធីសិលាបានបង្ហាញនូវ សមិទ្ធិផលយ៉ាងធំសម្បើម និងបានទទួលនូវជោគជ័យយ៉ាងធំធេងនៅក្នុងការធ្វើអោយបានសំរេចដល់គោលបំណងចំពោះមុខរបស់ខ្លួន ។ នេះវាក៏ជាការសន្និដ្ឋានរួមរបស់ក្រុមយើងផងដែរ ។ ដោយពិចារណាទៅលើ ខ្លឹមសារនៃកម្មវិធីសិលា មូលដ្ឋានប្រវត្តិសាស្ត្ររបស់វា និងការលំបាកព្រមទាំងកិច្ចការដ៏ធំធេងដែលបានបង្កើតដោយខ្លួនឯងនោះ ធ្វើអោយគ្មានការសង្ស័យនៅក្នុងគំនិតយើងឡើយថា កម្មវិធីសិលាបានទទួលជោគជ័យ លើសពីអ្វីដែលគេបានសង្ឃឹមទុក ។

ក្នុងខណៈដែលមិនទាន់បញ្ចប់សព្វគ្រប់ និង មិនទាន់មានភាពរលូននៅក្នុងគ្រប់ប្រការ កម្មវិធីសិលាបានបង្កើតនូវគោលគំនិតប្រតិបត្តិការដើម្បីរៀបចំផែនការ និង អភិវឌ្ឍន៍មូលដ្ឋាន និងតំបន់ ។ ដើម្បីបកស្រាយគោលគំនិតនេះទៅក្នុងការអនុវត្តន៍ សិលាបានធ្វើអោយមាននូវការរីកចំរើនយ៉ាងច្រើន ឆ្ពោះទៅរកការកសាងសមត្ថភាពប្រកបដោយនិរន្តរភាពនៅថ្នាក់ខេត្ត ស្រុក និងសហគមន៍នៅក្នុងខេត្តប្រាំ ។ ប្រហែលអ្វីដែលសំខាន់ជាងគេនោះ គឺសិលាបានធ្វើការផ្លាស់ប្តូរនូវចរិកលក្ខណៈរបស់ខ្លួនតាមសភាពជាក់ស្តែង ។ គឺបានធ្វើការផ្លាស់ប្តូរសហគមន៍ពីភាពជាអ្នករងចាំតែទទួលជំនួយ ក្លាយមកជាអ្នកដើរតួដោយពឹងផ្អែកលើខ្លួនឯងប្រកបដោយកំរិតនៃការជឿជាក់លើខ្លួនឯងគួរអោយកត់សំគាល់ ។ ដូចគ្នាផងដែរ ចរិកលក្ខណៈរបស់បុគ្គលិករដ្ឋាភិបាលថ្នាក់ខេត្ត និងស្រុកក៏មានការផ្លាស់ប្តូរទៅជាការកាន់តែមានការទទួលខុសត្រូវ និងជឿជាក់លើខ្លួនឯង ។ ដោយឡែក សិលាបានធ្វើអោយមានការរីកចំរើនគួរអោយកត់សំគាល់ ក្នុងការបង្កើននូវតំលៃប្រជាធិតេយ្យ និងអភិបាលកិច្ចល្អ ។ ក្រៅពីនេះវាត្រូវបានមើលឃើញយ៉ាងច្បាស់ថា សិលាបានជះឥទ្ធិពលយ៉ាងខ្លាំង ស្តីអំពីសហវិមជ្ឈការ និងជាពិសេសវិមជ្ឈការទៅលើគោលនយោបាយរបស់រដ្ឋាភិបាល ។ សិលាក៏បានបង្ហាញអោយឃើញផងដែរ នូវយន្តការប្រកបដោយប្រសិទ្ធភាពដើម្បីធ្វើអោយមានទំនាក់ទំនងល្អជាមួយនិងសហគមន៍អតីតខ្មែរក្រហម និងដើម្បីទាក់ទងជាមួយ ជនជាតិផ្សេងៗ ក្នុងសកម្មភាពនៃការប្រឹងប្រែងដើម្បីធ្វើការរួមរួម និងផ្សះផ្សាររបស់រដ្ឋាភិបាល ។ សិលាក៏បានផ្តល់ ផងដែរនូវសេវាចាំបាច់ជាមូលដ្ឋាន ដើម្បីឆ្លើយតបទៅនិងសេចក្តីត្រូវការរបស់សហគមន៍នៅក្នុងភូមិជាង ២០០០ ។

សិលាបានទទួលជោគជ័យក្នុងការទាក់ទាញនូវមូលនិធិ ។ ជាងពាក់កណ្តាលមូលនិធិដែលកម្មវិធី បានប្រើប្រាស់នៅពេល បច្ចុប្បន្ន គឺបានទទួលពីប្រភពផ្សេងៗទៀត ក្រៅពីប្រភពដែលបានចាប់ផ្តើមផ្តល់ ពីដំបូង ដូចជា : UNDP, SIDA និង UNCDF ។ ទាំងនេះគឺជាសាក្សីក្នុងការទទួលដឹងថា សិលាបានទទួលជោគជ័យក្នុងចំណោមភ្នាក់ងារផ្តល់ មូលនិធិទាំងឡាយ ។

យើងក៏បានកត់សំគាល់នូវកំរិតកំណត់ខ្លះៗរបស់កម្មវិធីសិលាផងដែរ ។ យើងត្រូវបានធ្វើអោយជឿជាក់យ៉ាងតិចតួចណាស់ថា សិលាបានជួយដោយផ្ទាល់ក្នុងការកាត់បន្ថយភាពក្រីក្រ ។ ទាំងទំហំព្រមទាំងលក្ខណៈនៃសេវាដែលបានចែកចាយ មិនបានផ្តល់នូវឥទ្ធិពលដែលគួរអោយកត់សំគាល់នោះឡើយ ។ គេបាននិយាយថា វាគួរតែត្រូវបានទឹកឃើញថា ការកាត់បន្ថយភាពក្រីក្រ វាមិនមែនជាគោលបំណងបន្ទាន់ ប៉ុន្តែវាជាគោលដៅយូរអង្វែងរបស់កម្មវិធី ។ ម្យ៉ាងទៀត សិលា បានមានលទ្ធភាពទៅដល់ចំនុចនៃនិរន្តរភាពយ៉ាងលំបាកជាទីបំផុតចំពោះរដ្ឋភាពបច្ចុប្បន្ន ដោយរួមទាំងប្រសិទ្ធភាព និងទាំងគុណភាព និងបន្តការពឹងផ្អែកទៅ លើសមត្ថភាពរបស់បុគ្គលិកគាំទ្ររបស់ឃែរេរ ។ ចំណែកឯភាពជាម្ចាស់ បានដើរតួសំខាន់ និងខ្លាំងជាងគេគឺនៅថ្នាក់ខេត្ត និងថ្នាក់ឃុំ ។ យើងបានយល់ឃើញថានៅថ្នាក់ជាតិមានលក្ខណៈខ្សោយនៅក្នុងភាពជាម្ចាស់នេះ និងថ្នាក់នេះមិនទាន់មានការយល់ដឹងអោយបានគ្រប់គ្រាន់ អំពីកម្មវិធីសិលា និងមានការដឹកនាំខ្សោយព្រមទាំងសមត្ថភាពនៃការគ្រប់គ្រងនៅមានកំណត់ ។ ដូចបានពិភាក្សា នៅក្នុងផ្នែក គ យើងបានយល់ឃើញថាចំនុចខ្លះៗនៃប្រពន្ធ័នេះ ត្រូវតែមានការកែសំរួលអោយប្រសើរឡើង និងធ្វើអោយមានភាពសមញ្ញធម្មតា ។ កំរិតកំណត់នេះមិនបានធ្វើអោយខូច ឬច្របូកច្របល់ដល់សេចក្តីសន្និដ្ឋានជាទូទៅ ដ៏ល្អប្រពៃទៅលើសមិទ្ធិផលដែលសំរេចបាននោះឡើយ ។

## ៣. កត្តាដែលធ្វើអោយមានជោគជ័យនៃកម្មវិធីសិលា

ប្រហែលជាកត្តាយ៉ាងសំខាន់ដែលនាំអោយមានជោគជ័យនៃកម្មវិធីសិលា គឺជាវិធីសាស្ត្រនៃការរៀនសូត្រដោយអនុវត្តផ្ទាល់ (រៀនបណ្តើរ អនុវត្តបណ្តើរ) ដែលត្រូវបានអោយអនុវត្តឡើងទាំងនៅក្នុងការអភិវឌ្ឍន៍គោលគំនិត និងនៅក្នុងសមាសធាតុរបស់វាព្រមទាំងនៅក្នុងការពង្រឹងសមត្ថភាពផងដែរ ។ ទាំងនេះត្រូវបានធ្វើអោយមានលទ្ធភាពទៅបាន ដោយសារ ការរួមបញ្ចូលមូលនិធិនៃការអភិវឌ្ឍន៍វិធីសាស្ត្រ ការកសាងសមត្ថភាព និងសកម្មភាពអភិវឌ្ឍន៍អោយទៅជាកញ្ចប់មួយ ដែលគ្រប់ដណ្តប់ទៅលើគ្រប់លំដាប់ថ្នាក់ទាំងអស់នៃអ្នកដើរតួក្នុងការអភិវឌ្ឍន៍។ ក្នុងនោះមាន គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត និងគណៈកម្មាធិការប្រតិបត្តិរបស់គេ មន្ទីរជំនាញសំខាន់ៗនៅថ្នាក់ខេត្ត និងថ្នាក់ស្រុកព្រមទាំងអង្គការចាត់តាំងនៅថ្នាក់សហគមន៍ផងដែរ ។ កត្តាសំខាន់ទីពីរដែលនាំអោយមានជោគជ័យគឺ បទពិសោធន៍ និងវិធីសាស្ត្ររៀនសូត្រនៃការខិតខំប្រឹងប្រែង ដែលមានការគាំទ្រយ៉ាងខ្លាំងនិងជាប់លាប់របស់រដ្ឋាភិបាល និងអ្នកផ្តល់ជំនួយទាំងឡាយ ។ វាគ្មានការសង្ស័យបន្តិចឡើយដែលថាការគាំទ្រយ៉ាងខ្លាំងក្លា និងប្រកបដោយគុណភាពខ្ពស់ ដែលបានផ្តល់ដោយ ឃែរេរ តាមរយៈ UNOPS ដល់កម្មវិធីសិលា បានដើរតួយ៉ាងសំខាន់ និងបន្តការគាំទ្រនេះយ៉ាងពិតប្រាកដទៀត ។ ក្នុងខណៈដែលបុគ្គលិកអន្តរជាតិមួយចំនួនត្រូវបានកាត់បន្ថយពីចំនួន អតិបរិមា គឺ ៣៧ នាក់ មកត្រឹមតែ ១០ នាក់នាពេលបច្ចុប្បន្ននេះ

បុគ្គលិកជំនួយបច្ចេកទេស ឃែរេរដែល ជ្រើសរើសនៅក្នុងស្រុក មានចំនួនមិនតិចជាង ១១០ នាក់ ដែលនៅក្នុងនោះ ប្រហែលជា ១ភាគ ៣ នៃចំនួនបុគ្គលិកនេះជាអ្នកផ្តល់ជំនួយបច្ចេកទេសដល់មន្ទីរជំនាញ ។ វាត្រូវតែបានទទួលស្គាល់ផងដែរថា ការប្រើប្រាស់ថវិកាសំរាប់ឧបត្ថម្ភបន្ថែមដល់បុគ្គលិករដ្ឋាភិបាលមានចំនួនប្រហែល ២៥០ នាក់ ដែលបុគ្គលិកទាំងនេះបានដើរតួយ៉ាងសំខាន់និងបន្តការដើតួរនេះទៀត ។

ក្នុងខណៈដែលកម្មវិធីសិលាប្រតិបត្តិក្នុងបរិបទសាំញ៉ាំស្មុគស្មាញ ប្រែប្រួល និង ក្នុងផ្នែកខ្លះដែលមិនអាចធ្វើការទស្សទាយ ឬសង្ឃឹមបាននោះ ទាំងនេះក៏ត្រូវបានក្លាយទៅជាគុណសម្បត្តិរបស់កម្មវិធីផងដែរ ។ នោះគឺនៅពេលដែលអ្នករៀបចំកម្មវិធីសិលា បានបញ្ចូលកម្មវិធីនេះអោយអនុវត្តទៅក្នុងខេត្តទាំង ៥ បុគ្គលិកដែលមានគុណភាព នៅក្នុងខេត្តភាគច្រើនបានអសកម្មភាព ខ្វះធនធាន និងការណែនាំ និងនៅចំពេលដែលកំពុងតែមានសេចក្តីត្រូវ ការជាបន្ទាន់ដើម្បីការផ្តល់ជំនួយ និងការអភិវឌ្ឍន៍ ។ ឃែរេរ ទី ១ និងបន្ទប់មកសិលា បានផ្តល់ឱកាសថាមភាព គំនិតថ្មីៗ កិច្ចការដែលមានអត្ថន័យច្បាស់លាស់ និងសេចក្តីពេញចិត្តនៃការងារដែលវាទាំងនេះក្លាយជាថាមពលយ៉ាងខ្លាំងក្លា និងការប្តេជ្ញាចិត្តដល់ការខិតខំប្រឹងប្រែងនេះ ។

ដូចគ្នានេះដែរ ការលូតលាស់នៃមហិច្ឆិតារបស់រដ្ឋាភិបាល ចំពោះលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសតទៅទៀតដោយបង្កើតឡើងនូវប្រពន្ធ័មួយសំរាប់រដ្ឋាភិបាលមូលដ្ឋានបានជួយដឹកនាំកម្មវិធីសិលា ឆ្ពោះទៅកាន់ការរីកចំរើនទៅមុខទៀត ។ ក្នុងពេលដែលរដ្ឋាភិបាលមានតែបទពិសោធន៍យ៉ាងច្រើនអំពីការធ្វើផែនការ និងការអភិវឌ្ឍន៍មូលដ្ឋាន និងតំបន់ ។ នោះកម្មវិធីសិលាបានក្លាយទៅជាកត្តា ឬគ្រឿងផ្សំយ៉ាងសំខាន់សំរាប់មិនត្រឹមតែក្នុងដំណើរការនៃការបង្កើត គោលនយោបាយប៉ុណ្ណោះទេ ថែមទាំងនៅក្នុងទស្សនៈនៃការប្រតិបត្តិការរបស់កម្មវិធីកែទំរង់សំរាប់វិមជ្ឈការ និងសហវិមជ្ឈការ ។

## គ. ការរកឃើញលំអិត

### ១. ការទទួលយកបាន និងភាពជាម្ចាស់នៃកម្មវិធីសិលា

ក្រុមបេសកកម្មមានឱកាសយ៉ាងច្រើនក្នុងការជួបពិភាក្សានៅថ្នាក់ខេត្ត ស្រុក ឃុំ និងភូមិ អំពីកម្មវិធីសិលា ។ នៅថ្នាក់ឃុំ និងភូមិ កំរិតនៃភាពទទួលយកបាននៃកម្មវិធីនេះ គឺវាទាក់ទង់ទៅនិងរយៈពេលដែលកម្មវិធីនេះប្រតិបត្តិការនៅទីនោះ ។ ចំពោះភាពទទួលយកបាននេះត្រូវបានសង្កេតឃើញថា នៅមុនពេលដែលបានទទួលផលប្រយោជន៍ដែលបានមកពីដំណើរការកសាងផែនការមូលដ្ឋាន ជាធម្មតាវាហាក់ដូចជាការសាកល្បង។ ប៉ុន្តែវាមានការកើនឡើងយ៉ាងខ្លាំង នៅពេលដែលលទ្ធផលជាក់លាក់បានក្លាយជារូបរាងឡើង ។ ទាំងនេះត្រូវបាន

បង្ហាញអោយឃើញច្បាស់នៅក្នុងតំបន់ធ្វើសមាហរណកម្មឡើងវិញ ដែលជាកន្លែងមានសកម្មភាពធ្វើផែនការយ៉ាងខ្លាំងក្លា តែត្រូវបានអនុវត្តដោយមានការយឺតយ៉ាវនៃការផ្តល់ថវិកា ។ ប្រជាជនមានការមន្ទិលសង្ស័យ និងស្ទាក់ស្ទើរក្នុងការបរិច្ចាគមូលនិធិហសគមន៍សំរាប់គំរោងការ មុនពេលសាងសង់ ឬអនុវត្តគំរោងនោះ ។ ទោះជាយ៉ាងណាក៏ដោយក៏នៅពេលដែលផែនការទាំងនេះបានក្លាយជាការពិត ឥរិយាបទរបស់ប្រជាជនបានកាន់តែក្លាយទៅជាមានការជឿជាក់ ។ បច្ចុប្បន្នមានឃុំដែលជិតខាងមួយចំនួនកាន់តែយល់ច្បាស់ អំពីកម្មវិធី និងឃុំមួយចំនួនមានបំណងចង់ចូលរួមជាមួយកម្មវិធីនេះយ៉ាងខ្លាំងក្លា ។ ជាទូទៅ ការអនុវត្តកម្មវិធីនេះវាត្រូវធ្វើទៅតាមរយៈវដ្តប្រចាំឆ្នាំរបស់វាដូចនេះភាពដែលអាចទទួលយកបាន និងការយល់ដឹងក៏ត្រូវបានកើនឡើនទៅតាមនោះដែរ ។ យោងទៅតាមដំណើរការធ្វើផែនការ និងការជ្រើសរើស អាទិភាពបញ្ហាដោយមានការចូលរួម និង ការចូលរួមបដិភាគទាំងថវិកា សំភារៈ និងពលកម្មរបស់ប្រជាជន បានធ្វើអោយអារម្មណ៍របស់ប្រជាជនចំពោះភាពជាម្ចាស់នៃសំភារៈ និងសមិទ្ធិផលដែលសំរេចបាននៅក្នុងតំបន់នោះមានកំរិតខ្ពស់ ។ ការចូលរួមរបស់គណៈកម្មការអភិវឌ្ឍន៍ភូមិ ឃុំមានលក្ខណៈល្អប្រពៃ និងការចូលរួមរបស់ប្រជាជនទាំងប្រុសទាំងស្រីក៏មានកំរិតខ្ពស់ដែរ ។ ភាពទទួលយកបានរបស់កម្មវិធីនៅថ្នាក់ខេត្ត និងថ្នាក់ស្រុកក៏ត្រូវបានមើលឃើញថាមានការកំរិតខ្ពស់ដែរ ។ តាមរយៈការប្រជុំជាមួយនិងគណៈកម្មាធិការប្រតិបត្តិរបស់ខេត្តទាំងបី បានបង្ហាញអោយឃើញថា ភាពជាម្ចាស់របស់គេលើកម្មវិធីមានកំរិតយ៉ាងខ្លាំងក្លា ។ កម្មវិធីសិលាវាមិនត្រឹមតែត្រូវបានមើលឃើញថាជាកម្មវិធីដ៏មានតំលៃនៅក្នុងការផ្ទេរចំណេះដឹងទេពកោសល្យ និងធនធានទៅអោយខេត្ត តែវាក៏ត្រូវបានមើលឃើញដែរថាវាជា គោលនយោបាយរបស់រដ្ឋាភិបាល និងជាគោលនយោបាយដែលបុគ្គលិក រដ្ឋាភិបាលនៅថ្នាក់ខេត្ត បានធ្វើការបរិច្ចាគយ៉ាងសំខាន់ ។ តាមរយៈការប្រជុំជាមួយមន្ទីរជំនាញក៏បានទទួលនូវមតិល្អៗជាច្រើនអំពីតំលៃនៃកម្មវិធីដែលមានចំពោះខេត្ត មន្ទីរជំនាញ និងសហគមន៍មូលដ្ឋាន ។

ក្រុមបេសកកម្មក៏បានជួបប្រជុំជាមួយក្រុមអ្នកម៉ៅការ ដែលជាអ្នកដេញថ្លៃម៉ៅការសាងសង់ សំរាប់ការអនុវត្តសកម្មភាពគំរោងឃុំដែលបានទទួលថវិកាពីមូលនិធិអភិវឌ្ឍន៍មូលដ្ឋាន ។ ពួកគេបានប្រាប់ពីទិដ្ឋភាពដ៏ប្រពៃរបស់កម្មវិធី ពេញចិត្តអំពីតម្លាភាពនៃដំណើការដេញថ្លៃ ដែលធ្វើអោយពួកគេអាចបំពេញការងាររបស់គេបានចប់សព្វគ្រប់ ។

ថ្វីត្បិតតែនៅមានការមន្ទិលសង្ស័យការពីដើមដំបូង តែមកដល់ពេលនេះអង្គការក្រៅរដ្ឋាភិបាលនានា ដែលធ្វើការនៅក្នុងខេត្តដែលមានកម្មវិធីសិលា ឃើញដូចជាមានការទទួលស្គាល់កម្មវិធីនេះហើយជាទូទៅបានធ្វើការសហការក្នុងការងារអភិវឌ្ឍន៍ភូមិ ។ អង្គការក្រៅរដ្ឋាភិបាលនានា បានរៀបរាប់អំពីចំនុនវិជ្ជមានជាច្រើនរបស់

កម្មវិធីសិលា ។ រចនាសម្ព័ន្ធអភិវឌ្ឍន៍មូលដ្ឋានដែលបានបង្កើតឡើងដោយកម្មវិធីសិលា ជួយពួកគេក្នុងការធ្វើការងារនៅក្នុងភូមិ និង ឃុំ ។ ពិតមានដែលផ្តល់ដោយទិន្នន័យជាមូលដ្ឋានរបស់ឃុំ ជួយពួកគេក្នុងការជ្រើសរើសសហគមន៍គោលដៅ ។ សិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុកអាចអនុញ្ញាតិ អោយពួកគេបានពិភាក្សាលើអាទិភាពបញ្ហារបស់សហគមន៍ និងធ្វើការចរចាគ្នាពីការសហការឆ្លើយតបជាមួយនិងតំណាងសហគមន៍ និងមន្ទីរជំនាញ ។

ភាពដែលអាចទទួលយកបាននិងភាពជាម្ចាស់នៅថ្នាក់ជាតិ ហាក់ដូចជាមានភាពមិនច្បាស់លាស់ច្រើនជាង ។ ក្រុមគ្រប់គ្រងនៅថ្នាក់ជាតិ គឺជាក្រុមដឹកនាំការងារសិលា ដែលមានសមាជិកតំណាងមកពី ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងផែនការ ក្រសួងកសិកម្ម ក្រសួងកិច្ចការនារី ក្រសួងមហាផ្ទៃ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។ ក្រុមដឹកនាំការងារសិលានេះមានលេខាធិការដ្ឋានតូចមួយរបស់ខ្លួន ដែលបានទទួលការគាំទ្រដោយបុគ្គលិកជំនួយការបច្ចេកទេសបរទេសម្នាក់ ។ ក្រុមដឹកនាំការងារសិលា និងលេខាធិការដ្ឋានធ្វើការសំរបសំរួលជាមួយក្រសួងនានា និង មន្ទីរជំនាញនៅតាមខេត្ត តាមរយៈជនបង្គោលនៅក្នុងក្រសួងទាំងនោះដែលអ្នកទាំងនោះគឺជាដៃគូការងាររបស់លេខាធិការដ្ឋាន ។ តាមការប្រជុំរបស់យើងជាមួយពួកគេ យើងទទួលដឹងថានៅថ្នាក់នេះគ្មានការព្រមព្រៀងច្បាស់លាស់អំពីកម្មវិធីសិលា ឬ តួនាទីការងាររបស់គេនៅក្នុង កម្មវិធីនេះ ។ ក្នុងករណីខ្លះ សំដីនៃការសន្យា ឬការប្តេជ្ញាចិត្តយ៉ាងខ្លាំងក្លាចំពោះការបង្កើតក្រុមដឹងនាំការងារសិលា ត្រូវបានឃើញថាមានភាពប្រែប្រួលទៅតាមកាលៈទេសៈ ។ ក្នុងខណៈដែល ក្រុមដឹកនាំសិលា បង្កើតនូវតួនាទីដ៏មានតំលៃក្នុងការផ្តល់សិទ្ធិដល់កម្មវិធីនៅក្នុខេត្តសិលា សមាជិកក្រុមនេះមានការប្រែប្រួលនូវការបកស្រាយរបស់គេ អំពីអត្ថន័យនៃភាពទទួលយកបានរបស់គោលគំនិតសិលា ។ ទាំងនេះអាចយល់បានថា ដោយហេតុតែក្រុមនេះនៅថ្មីពេកសំក្នុងការប្រតិបត្តិការកិច្ចការក្នុងបរិបទនៃកែទំរង់រដ្ឋបាលដែលមានភាពមិនទាន់ច្បាស់លាស់ ។ សមាជិកក្រុមដឹកនាំសិលា និងជនបង្គោលពេលខ្លះក៏មានទំនាស់ស្ថាប័នដែរ ។

## ២. ភាពសមរម្យនៃគំរូរបស់កម្មវិធីសិលា

គំរូរបស់កម្មវិធីសិលា ត្រូវបានកើតឡើងពីផ្នែកជាច្រើន ដែលក្នុងនោះមាន ផ្នែកហិរញ្ញវត្ថុ ផែនការតួនាទីបុរស-ស្ត្រី គ្រប់គ្រង និងផ្នែកត្រួតពិនិត្យនិងវាយតំលៃ ។ ផ្នែកនិមួយៗនេះនិងត្រូវពិភាក្សា ដូចតទៅនេះ :

ក- ប្រពន្ធ័ហិរញ្ញវត្ថុ

មូលនិធិសំរាប់សកម្មភាពអភិវឌ្ឍន៍ថ្នាក់មូលដ្ឋាន និងថ្នាក់តំបន់ ក្នុងកម្មវិធីសិលាត្រូវបានផ្ទេរទៅដល់ថ្នាក់ខេត្តតាមបីរបៀប ។ មូលនិធិរបស់ UNDP ត្រូវបានផ្ទេរទៅខេត្តដោយផ្ទាល់តាមរយៈគណនីពិសេស

របស់គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ។ មូលនិធិពី IFAT និង WORLD BANK ត្រូវបានផ្ទេរតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អោយទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត ។ មន្ទីរនេះធ្វើការផ្ទេរមូលនិធិនេះ អោយទៅគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្តដើម្បីដំណើរការ ។ ចំណែកឯមូលនិធិចូលរួមរបស់រាជរដ្ឋាភិបាលត្រូវបានផ្ទេរអោយទៅរតនាគារថ្នាក់ខេត្ត ។ រតនាគារខេត្តជាអ្នកប្រតិបត្តិការមូលនិធិនេះដូចជាបេឡាករ ។ ដូចគ្នានេះដែរផ្នែកហិរញ្ញវត្ថុ របស់គណៈកម្មាធិការប្រតិបត្តិខេត្តបំពេញតួនាទី ជាអ្នកត្រួតពិនិត្យថវិកាទាំងនេះ ។ អភិបាលខេត្តគឺជាមន្ត្រីអនុម័តលើមូលនិធិទាំងអស់នេះ ។

ចំនុចគួរអោយកត់សំគាល់នៃប្រពន្ធ័គ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយតម្លាភាព និងប្រសិទ្ធិភាព វាមានការលំបាកសំរាប់ការទាមទារអោយមានការបរិយាយលំអិត ។ យើងបានជួបប្រជុំជាមួយនិងបុគ្គលិកដែលមកពីក្រសួង និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត ហើយបានទទួលស្គាល់ថា ប្រពន្ធ័គ្រប់គ្រងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលដែលមានស្រាប់ ដោយរាប់បញ្ចូលទាំងប្រពន្ធ័គណនេយ្យផង ត្រូវតែធ្វើការកែលំអរ អោយបានច្រើន ។

រហូតមកដល់ ខែមិថុនា ឆ្នាំ ១៩៩៩ ឃែរេរេ បានគ្រប់គ្រងមូលនិធិ ដែលបានផ្តល់ដោយ UNDP ។ ឃែរេរេប្រចាំខេត្ត ធ្វើការបើកមូលនិធិទាំងនេះអោយទៅ មន្ទីរជំនាញ គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ឬភ្នាក់ងារអភិវឌ្ឍន៍ផ្សេងទៀត ក្រោយពីបានទទួលនូវសំណើរ និងរបាយការណ៍ហិរញ្ញវត្ថុ ។ ចាប់តាំងពីខែ មិថុនា ១៩៩៩ ជំហានសំខាន់មួយត្រូវបានអនុវត្តឡើងដោយបញ្ចូលកម្មវិធីសិលាទៅក្នុងរចនាសម្ព័ន្ធ រដ្ឋាភិបាល និងធ្វើការពង្រឹងអំណាចនៃរចនាសម្ព័ន្ធនេះ ដោយផ្ទេរការទទួលខុសត្រូវក្នុងការគ្រប់គ្រងមូលនិធិ នេះអោយទៅអជ្ញាធរខេត្តដែលត្រូវបានហៅថា គណៈកម្មាធិការប្រតិបត្តិ ។ មុននឹងមានការផ្ទេរនេះ ប្រពន្ធ័គ្រប់គ្រងហិរញ្ញវត្ថុនិងគណនេយ្យថ្មីត្រូវបានគេបង្កើតរួចជាស្រេច ហើយបច្ចុប្បន្ននេះ គេបានប្រតិបត្តិនូវប្រពន្ធ័នេះបានប្រហែល ៨ ខែមកហើយ ។

ប្រពន្ធ័ថ្មីនេះត្រូវបានធ្វើការកែច្នៃយ៉ាងល្អ និងឆ្លើយតបទៅនិងក៏រិតអន្តរជាតិ ដែលជាទូទៅត្រូវបានទាមទារដោយភ្នាក់ងារផ្តល់ជំនួយ ។ ប្រពន្ធ័នេះ វាបានផ្តល់នូវតម្លាភាព បង្ហាញសំរាប់ការគ្រប់គ្រង និងត្រួត ពិនិត្យផ្ទៃក្នុង ។

យោងតាមប្រពន្ធ័ហិរញ្ញវត្ថុថ្មីនេះ ដែលមានបញ្ចូលទាំងផ្នែកសំរាប់អោយមានការធ្វើសវនកម្មពីខាងក្រៅផងនោះ យើងសូមផ្តល់ជាអនុសាសន៍ថា ចំពោះគ្រប់អ្នកផ្តល់ជំនួយទាំងអស់ ដែលផ្តល់មូលនិធិ អោយកម្មវិធីសិលាគួរតែធ្វើការផ្តល់មូលនិធិនេះតាមរយៈរចនាសម្ព័ន្ធរដ្ឋាភិបាល (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) និងត្រូវតែបានរាប់បញ្ចូលទៅក្នុងថវិកាជាតិផងដែរ ។ ធ្វើដូច្នេះ ដើម្បីពង្រឹងនូវភាពជាម្ចាស់ បង្កើននូវ លទ្ធភាពរបស់រដ្ឋាភិបាល កណ្តាលក្នុងការត្រួតពិនិត្យលើលទ្ធភាព និងការប្រើប្រាស់ធនធាន ទាំងឡាយ និង ព្រមទាំងជួយជំរុញសហវិមជ្ឈការ ។

ការពិភាក្សាជាមួយនិងអ្នកប្រើប្រាស់ប្រពន្ធ័ហិរញ្ញវត្ថុថ្មីនេះ ពួកគេបានអោយយោបល់ថា វាមានដំណើរការដោយគ្មានបញ្ហាធំដុំឡើយ ។ ទាំងនេះគ្មានអ្វីគួរអោយមានការភ្ញាក់ផ្អើលឡើយ ព្រោះបុគ្គលិកដែលបានធ្វើដំណើរការប្រពន្ធ័នេះ គេមានចំណេះដឹងផ្នែកគណនេយ្យសមល្មម និងត្រូវបានទទួលការបណ្តុះបណ្តាលគ្រប់គ្រាន់ និងព្រមទាំងការជួយជាប្រចាំពីបុគ្គលិកយែរេរ ។ នៅឯថ្នាក់ខេត្ត យើងត្រូវគេនិយាយប្រាប់ថាបើមានការបណ្តុះបណ្តាលទៀតនោះ វាកាន់តែបានផលប្រយោជន៍ល្អ ។ ប៉ុន្តែចំពោការបណ្តុះបណ្តាលដែលបានទទួលហើយនោះ វាមានការរៀបចំល្អ និងគ្រប់គ្រាន់ទៅហើយ ។ ដោយយោងតាមបទពិសោធន៍មកដល់បច្ចុប្បន្ន នៅក្នុងខេត្តទាំងពាដែលយើងបានទៅនោះ ឃើញថាគ្មានបញ្ហាធំដុំក្នុងប្រពន្ធ័ដែលបានដំណើរការនោះ គេបានផ្តល់យោបល់ថា ការផ្ទេរមូលនិធិនិងការទទួលខុសត្រូវនេះបានប្រព្រឹត្តទៅដោយរលូន ហើយប្រពន្ធ័នេះ គឺជាប្រពន្ធ័ដែលអាចអោយយកទៅអនុវត្តតាមបានយ៉ាង សមរម្យ ។

ចំនុចមួយនៃប្រពន្ធ័ហិរញ្ញវត្ថុដែលធ្វើអោយយើងចាប់អារម្មណ៍នោះគឺ តួនាទីរបស់គណៈកម្មការ អភិវឌ្ឍន៍ឃុំក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ ។ នៅក្នុងខេត្តដែលយើងបានធ្វើទស្សនកិច្ច ជាទូទៅឃើញថាសិលា បានធ្វើការដកចេញនូវស្ថានភាពនៃការទទួលខុសត្រូវក្នុងការផ្ទេរមូលនិធិទៅអោយ គណៈកម្មការអភិវឌ្ឍន៍ ឃុំដើម្បីធ្វើការទូទាត់អោយទៅអ្នកម៉ៅការ ទៅជាស្ថានភាពនៃការទូទាត់ផ្ទាល់ដែលត្រូវធ្វើឡើងដោយគណៈកម្មាធិការប្រតិបត្តិ ។ ការផ្ទេរការទទួលខុសត្រូវ និងការគ្រប់គ្រងមូលនិធិអោយទៅគណៈកម្មការអភិវឌ្ឍន៍ឃុំ អាចជាការត្រឹមត្រូវវាដូចជាវិធីដ៏សំខាន់មួយក្នុងការពង្រឹងអំណាចរបស់គេ ។ តាមអ្វីដែលយើងបានដឹងគឺ មូលហេតុដែលធ្វើអោយមានការទូទាត់ផ្ទាល់ដោយគណៈកម្មាធិការប្រតិបត្តិ គឺទាក់ទងទៅនិងលំហូរមូលនិធិ និងបញ្ហានៃប្រសិទ្ធិភាពនិងដើម្បីភាពងាយស្រួល ។ យើងមិនបានរកឃើញថា ជាពិសេសចំពោះមូលហេតុនៃលំហូរមូលនិធិថាជាបញ្ហាដែលធ្វើអោយយើងជឿបានឡើយ ។ ផ្ទុយមកវិញយើងកត់សំគាល់ឃើញថា គណៈកម្មការអភិវឌ្ឍន៍ឃុំមួយចំនួនពួកគេក៏មើល ទៅឃើញថាវាជារឿងធម្មតា និងជាការ រៀបចំចាត់ចែងដ៏សាមញ្ញ ។

ទោះជាយ៉ាងណាក៏ដោយ ក៏នៅក្នុងច្បាប់ថ្មី ក្រុមប្រឹក្សាឃុំនឹងធ្វើការគ្រប់គ្រងមូលនិធិផ្ទាល់របស់គេ ។ ករណីនេះយើងសូមផ្តល់អនុសាសន៍ថា សិលាត្រូវពិចារណាលើគោលនយោបាយស្តីពីនីតិវិធីនៃការ ទូទាត់អោយទៅអ្នកម៉ៅការ គួរតែផ្ទេរការទទួលខុសត្រូវនេះអោយទៅគណៈកម្មការអភិវឌ្ឍន៍ឃុំ ក្នុងពេលណាដែលអាចធ្វើទៅបាន និងត្រូវតែអនុវត្តនូវការខិតខំប្រឹងប្រែងក្នុងការពង្រឹងសមត្ថភាពជាចាំបាច់ និងដោយក្តីសង្ឃឹមចំពោះស្ថាភាពនាពេលអនាគត ។

## ខ- ដំណើរការកសាងផែនការមូលដ្ឋាន

គោលបំណងចំបងរបស់ដំណើរការកសាងផែនការមូលដ្ឋាន គឺដើម្បីរៀបចំគំរោងស្នើសុំដែលដឹកនាំដោយសហគមន៍ សំរាប់ការអភិវឌ្ឍន៍ និងដើម្បីធ្វើការវិភាជន៍ធនធានអោយទៅគំរោងអាទិភាព ។ ដំណើរការនេះមាន ៥ជំហាន គឺ : ការណែនាំណែនាំដំបូងដល់គណៈកម្មការអភិវឌ្ឍន៍ឃុំនិមួយៗ សិក្ខាសាលាថ្នាក់ភូមិដើម្បីកំណត់អាទិភាពបញ្ហា សិក្ខាសាលាថ្នាក់ឃុំដើម្បីបង្កើតផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគប្រចាំឆ្នាំ សិក្ខាសាលាសមាហរណកម្មធ្វើឡើងនៅទីរួមស្រុក និងសិក្ខាសាលាថ្នាក់ឃុំម្តងទៀត ដើម្បីរៀបចំផែនការវិនិយោគឃុំ ។ ក្រៅពីនេះ នៅតាមភូមិនិមួយៗប្រជុំគ្នាបំពេញចំលើយសំរាប់សំណួរ ដើម្បីរៀបចំ សៀវភៅទិន្នន័យភូមិ ។

ដំណើរការកសាងផែនការមូលដ្ឋាននេះត្រូវបានរៀបចំឡើងដោយមានជំនួយពីក្រុមសំរបសំរួលខេត្ត និងក្រុមសំរបសំរួលស្រុក ។ ក្រុមទាំងពីនេះធ្វើការពន្យល់វិធីសាស្ត្រ និងបច្ចេកទេស ដែលទាក់ទងទៅនឹងគណៈកម្មការអភិវឌ្ឍន៍ឃុំ និងភូមិ និងជួយសំរបសំរួលពួកគេតាមគ្រប់ជំហាននៃដំណើរការនេះ ។ ទោះបីមានការកែប្រែដំណើរការនាពេលបច្ចុប្បន្ននេះអោយមានលក្ខណៈសាមញ្ញជាងមុនក៏ដោយ ក៏នៅមានផ្នែកខ្លះនៅតែមានលក្ខណៈស្មុគស្មាញ ជាពិសេសគឺវិធីសាស្ត្រក្នុងការជ្រើសរើស និងដាក់ពិន្ទុ ការចាត់លំដាប់ថ្នាក់នៃគំរោងស្នើសុំរបស់ភូមិដោយផ្អែកទៅលើទិន្នន័យគ្រួសារក្នុងភូមិ ។ ការប្រមូលទិន្នន័យ គឺទាមទារអោយអ្នកសំរបសំរួល ធ្វើការបណ្តុះបណ្តាលដល់អ្នកគណនា ត្រួតពិនិត្យសំនួរ ត្រួតពិនិត្យការបញ្ចូលពត៌មានទទួលទៅក្នុងទិន្នន័យមូលដ្ឋានដោយកុំព្យូទ័រ ។ តាមការអនុវត្តជាក់ស្តែង អ្នកសំរបសំរួលគ្មានពេលគ្រប់គ្រាន់ សំរាប់ធ្វើការងារទាំងនេះប្រកបដោយប្រសិទ្ធភាពឡើយ ។ អ្នកប្រើប្រាស់ទិន្នន័យនេះបានតវ៉ាថាទិន្នន័យនេះមានគុណភាពមិនសូវល្អ ហើយយើងមានការសង្ស័យថាប្រហែលជាគណៈកម្មការអភិវឌ្ឍន៍ឃុំបានរំលងចោលនូវចំណុចខ្លះៗ ។ យើងក៏បានសួរថាតើ ការវិភាគបច្ចេកទេសបានធ្វើការវិភាគច្រើនពេកទៅលើអ្វីដែលគណៈកម្មការអភិវឌ្ឍន៍បានដឹងអំពីសហគមន៍របស់គេ ឬក៏មានការសំរេចចិត្តដែលមានឥទ្ធិពលគួរអោយកត់សំគាល់ទៅលើការប្រើប្រាស់មូលនិធិអភិវឌ្ឍន៍មូលដ្ឋាន ។ ព្រោះនៅទីបំផុត អ្នកភូមិទាំងអស់នៅក្នុងឃុំគេត្រូវការគំរោងប្រភេទហេដ្ឋារចនាសម្ព័ន្ធមួយចំនួន ហើយគណៈកម្មការអភិវឌ្ឍន៍ឃុំក៏មានការឆ្លាតវៃក្នុង ការចែកអោយភូមិនិមួយៗបានទទួលធនធានស្មើៗគ្នា ។

ដូច្នេះយើងសូមផ្តល់អនុសាសន៍ថា ដំណើរការក៏សាងផែនការមូលដ្ឋានត្រូវតែធ្វើអោយមានភាពកាន់តែសាមញ្ញបន្តទៅទៀត ។ ទាំងនេះត្រូវតែកែសំរួលនៅក្នុងករណីខ្លះៗ ដោយហេតុថាអ្នកសំរបសំរួលទាំងនោះមិនអាចមានលទ្ធភាពទទួលនូវបន្ទុកការងារ ដែលកើតឡើងនៅពេលដែលតម្រូវអោយមានការពង្រីកកម្មវិធីសិលានេះទៅក្នុងស្រុក និងឃុំបន្ថែមទៀតឡើយ ។ គួរតែចាត់វិធានការដើម្បីកាត់បន្ថយនូវផ្នែកខ្លះៗ ដែលធ្វើអោយខុសគ្នាតែ

បន្តិចបន្តួចនោះចំពោះលទ្ធផល និងដើម្បីកាត់បន្ថយសេចក្តីត្រូវការជំនួយពីអ្នកសំរបសំរួល ។ ការប្រមូលទិន្នន័យសំរាប់ការធ្វើផែនការអាចធ្វើអោយបានងាយស្រួលបំផុត តាមរយៈការ វាស់ស្ទាបស្ទង់ ឫសិក្សាដោយកន្លែងចោះៗ ដែលរបៀបនេះអាចជួយកែលំអរគុណភាព និងបាត់ពិតមានយ៉ាង តិចបំផុត ។

អ្នកខ្លះបានសួរអំពីការ ផ្លាស់ប្តូរនៃការផ្តោតការយកចិត្តទុកដាក់ទៅលើការពង្រឹងសមត្ថភាព និងដំណើរការកសាងផែនការរបស់គណៈកម្មការអភិវឌ្ឍន៍ភូមិ ទៅគណៈកម្មការអភិវឌ្ឍន៍ឃុំ ។ ពួកគេមានការព្រួយបារម្ភថា វាអាចធ្វើអោយមានការថយចុះនៃការចូលរួមរបស់អ្នកភូមិក្នុងការធ្វើសេចក្តីសំរេចចិត្ត និងធ្វើអោយអន្តរាយដល់ការខិតខំប្រឹងប្រែងក្នុងការពង្រឹងការជឿជាក់ និងទុកចិត្តចំពោះកម្មវិធីសិលា ។ នេះគឺជា ការពិចារណាយ៉ាងត្រឹមត្រូវតាមច្បាប់ និងអ្នកគ្រប់គ្រងកម្មវិធីបានយល់ឃើញថា វាមិនមែនជាការងាយស្រួលទេ ក្នុងអនុវត្តឬចំលងតាមនៃកម្មវិធីដែលមានទំហំដ៏ធំធេងនេះ ។ នៅពេលដែលកម្មវិធីបានចាប់ផ្តើម ពង្រីកនូវចំនួនស្រុក និងឃុំរបស់ខ្លួន ពេលនោះវាបានធ្វើអោយដឹងច្បាស់ថា វាមិនអាចមានលទ្ធភាពនិងធ្វើអោយមានធនធានគ្រប់គ្រាន់ឡើយ និងកាន់តែតម្រូវអោយមានវិធីសាស្ត្រប្រកបដោយតំលៃប្រសិទ្ធភាពខ្ពស់ ។

ដំណើរការកសាងផែនការបច្ចុប្បន្ន ការពារអោយមានការការចូលរួមរបស់ប្រជាជន និងពង្រីកអោយមានការជឿជាក់តាមវិធានការផ្សេងៗ។ វិធីនោះមានរាប់បញ្ចូលទាំងការបង្កើតគណៈកម្មការអភិវឌ្ឍន៍ភូមិដោយការបោះឆ្នោត សិក្ខាសាលាថ្នាក់ភូមិដើម្បីកំណត់បញ្ហាជាអាទិភាព ការបញ្ចូលអ្នកតំណាងភូមិពីរនាក់ទៅក្នុងគណៈកម្មការអភិវឌ្ឍន៍ឃុំ និងការចូលរួមរបស់អ្នកភូមិក្នុងការរៀបចំ និងអនុវត្តគំរោង ។ ការពង្រឹងសមត្ថភាពរបស់ដល់គណៈកម្មការអភិវឌ្ឍន៍ភូមិនិងឃុំដោយកម្មវិធីសិលា នេះគឺជាធនធានដ៏មានតំលៃសំរាប់ក្រុមប្រឹក្សាឃុំនៅពេលអនាគត ។ យើងសូមផ្តល់អនុសាសន៍ថា វិធានការទាំងនោះ ត្រូវតែបានរក្សា ។

ជំហានមួយសំខាន់និងធ្វើអោយមានការចាប់អារម្មណ៍ខ្លាំងនោះ គឺជាសិក្ខាសាលាសមាហរណកម្មនៅថ្នាក់ស្រុក ។ នេះគឺជាវិធីសាស្ត្របញ្ចូលថ្មីដែលវាអាចអនុញ្ញាតិអោយ អ្នកតំណាងពីគណៈកម្មការអភិវឌ្ឍន៍ឃុំ មន្ទីរជំនាញ និងអង្គការក្រៅរដ្ឋាភិបាលដែលមានការចាប់អារម្មណ៍ បានចូលរួមផ្លាស់ប្តូរពិតមាន និងធ្វើការព្រមព្រៀងគ្នាលើសកម្មភាពដែលត្រូវអនុវត្ត ។ សំខាន់ជាងនេះទៅទៀត គឺវាបានផ្តល់ឱកាសដល់គណៈកម្មការអភិវឌ្ឍន៍ឃុំមានលទ្ធភាពក្នុងការជ្រើសរើសប្រភេទសេវាជាមួយអ្នកផ្តល់សេវាផ្ទាល់ និងវាក៏ជាឱកាសដើម្បីបង្កើនតម្រូវការរបស់ពួកគេ និងគៀងគរធនធានដោយមិនពឹងផ្អែកលើអ្នកនាំពាក្យឡើយ ។ យើងសូមផ្តល់អនុសាសន៍ថា ការប្រឹងប្រែងដោយរួបរួមព្រមព្រៀងគ្នា ត្រូវតែបានធ្វើឡើងដើម្បីជំរុញអោយមានការចូលរួមពីមន្ទីរជំនាញ និងអង្គការក្រៅរដ្ឋាភិបាលនានា នៅក្នុងសិក្ខាសាលានេះ។

មានបញ្ហាពីរដែលមិនទាន់ច្បាស់លាស់ គឺ ទីមួយគឺទាក់ទងទៅនិងពេលវេលានៃការធ្វើផែនការវិនិយោគសហគមន៍ និងការជំពាក់ទាក់ទងក្នុងការរៀបចំកិច្ចសន្យា និងការសាងសង់ ។ ដោយហេតុថា គណៈកម្មការអភិវឌ្ឍន៍ឃុំមិនបានទទួលនូវពិតមានអំពីការបែកចែកថវិកាវិភាជន៍ពីដើមឆ្នាំ ហេតុនេះហើយដំណើរការដេញថ្លៃ ការរៀបចំកិច្ចសន្យា និងការសាងសង់ត្រូវបានធ្វើឡើងយ៉ាងមមារញឹកនៅដើមរដូវភ្លៀង ។ ពេលដែលសិលាពង្រីកកម្មវិធីរបស់ខ្លួនទៅក្នុងស្រុក និងឃុំថ្មីផ្សេងទៀត អ្នកសំរបសំរួល និងបុគ្គលិកគាំទ្របច្ចេកទេស មិនអាចទទួលនូវបន្ទុកការងារដែលកើនឡើងនោះ ទាន់ពេលបានឡើយ ។ ដូចនេះយើងសូមផ្តល់អនុសាសន៍ថា វិធីដែលត្រូវដើរក្នុងការផ្តល់មូលនិធិអភិវឌ្ឍន៍មូលដ្ឋានគឺធ្វើឡើង សំរាប់ពីរឆ្នាំម្តង ដើម្បីអោយការរៀបចំកិច្ចសន្យា និងការសាងសង់អាចបានធ្វើឡើងក្នុងរយៈពេលពេញមួយឆ្នាំ នៃឆ្នាំនិមួយៗ។ នីតិវិធីក្នុងការជ្រើសរើសអ្នកម៉ៅការនាពេលបច្ចុប្បន្នមានលក្ខណៈល្អប្រសើរ និង គួរតែត្រូវបានថែរក្សាអោយនៅដដែល ។ ការចុះឈ្មោះ និងចំណាត់ថ្នាក់អ្នកម៉ៅការទៅលើសមត្ថភាព សំភារៈ និងពេលវេលាផ្តល់សេវា ធ្វើអោយមានភាពងាយស្រួលក្នុងជ្រើសរើសនៅទីបញ្ចប់ ។ តែការពិភាក្សាដែលនៅមានកំរិតនោះ គឺចំពោះសំណួរអំពីតំលៃ ។

បញ្ហាផ្សេងទៀតដែលទាក់ទងទៅនិងមូលនិធិអភិវឌ្ឍន៍មូលដ្ឋាននោះ គឺ មូលនិធិនេះត្រូវអោយប្រើប្រាស់តែទៅលើគំរោងហេដ្ឋារចនាសម្ព័ន្ធទ្រង់ទ្រាយតូចៗ ដូចជា លូទឹក ផ្លូវលំ និងអណ្តូងទឹកជាដើម ។ គំរោងទាំងនេះគឺជាអាទិភាពដែលត្រូវបានកំណត់តាំងពីឆ្នាំដំបូង។ យើងសូមផ្តាល់អនុសាសន៍ថា ប្រភេទគំរោងដែលត្រូវដាក់អោយជ្រើសរើស គួរតែមានភាពទូលំទូលាយដោយក្នុងនោះគួររាប់បញ្ចូលទាំងការងារ និងសេវាសាធារណៈផ្សេងៗទៀត តែមិនមែនសកម្មភាពសេដ្ឋកិច្ច ដែលសកម្មភាពនោះគួរតែបញ្ជាក់ក្នុងផ្លូវដទៃទៀត ។ អ្នកសំរបសំរួលមិនត្រូវផ្តល់ដំណឹង នៃសកម្មភាពសមរម្យដទៃទៀតឡើយ និងត្រូវជំរុញលើកទឹកចិត្តអោយសហគមន៍ធ្វើការពិចារណាលើសកម្មភាព ទាំងនោះ ។

គ- <u>ដំណើរការកសាងផែនការខេត្ត</u>

ដំណើរការកសាងផែនការខេត្តមិនបានបង្កើតបានល្អដូច ដំណើរកាកសាងផែនការមូលដ្ឋានឡើយ ។ វាកំពុងនៅតែមានការពាក់ពន្ធ័ និងនៅតែមានការបន្តការពាក់ពន្ធ័បន្តទៅទៀត ជាមួយនិងការកែរែបទំរង់រដ្ឋបាលដែលកំពុងតែរៀបចំនៅថ្នាក់ជាតិ ។ ការចាប់អារម្មណ៍ជាទូទៅនោះ គឺ ការរៀបចំដំណើរការដែលបង្កើនការធ្វើផែនការតាមបែបសហវិមជ្ឈការ និងបែបវិមជ្ឈការ និងដើម្បីបង្កើនការសំរបសំរួលគំរោង និងកម្មវិធីដោយអ្នកដើរតួរនៅថ្នាក់ឃុំ ខេត្ត និងថ្នាក់ជាតិ ។

ផ្នែកសំខាន់នៃការធ្វើផែនការគឺ ផែនការអភិវឌ្ឍន៍ខេត្ត កម្មវិធីវិនិយោគសំរាប់ការអភិវឌ្ឍន៍ខេត្ត និង កម្មវិធីអភិវឌ្ឍន៍សិលា ។ ផែនការអភិវឌ្ឍន៍ខេត្ត មានលើកឡើងអំពីទស្សនៈវិស័យទូទៅ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍នៅក្នុងខេត្ត ។ ប៉ុន្តែផែនការដែលបានបង្កើតដល់ពេលនេះមានកំរិតកំណត់ចំពោះទំហំ និង វាមានរូបរាងច្បាស់លាស់ជាងក្នុងផ្នែកណាដែលមានសង្ឃឹមថាអាចមានមូលនិធិ ។ គេមានការយកចិត្តទុកដាក់យ៉ាងតិចតួច ចំពោះការអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋាន ទីក្រុង ឬ ទំនាក់ទំនង និង ភាពពាក់ពន្ធ័គ្នាទៅវិញទៅមករវាង ទីក្រុង និងជនបទ ។ ដូច្នេះចំពោះគោលដៅមួយរបស់សិលាក្នុងការកាត់បន្ថយភាពក្រីក្រ យើងសូមផ្តល់អនុសាសន៍ថា ត្រូវតែមានការជួយបន្ថែមក្នុងការរៀបចំនូវវិធីសាស្ត្រនៃការផ្សារភ្ជាប់គ្នា ឬទំនាក់ទំនងក្នុងបញ្ហានេះអោយបានល្អជាមុន និង ត្រូវធ្វើអោយផែនការនេះក្លាយទៅជាឧបករណ៍ដែលគួរអោយជឿបានសំរាប់ការណែនាំក្នុងការតំរង់ទិសនាពេលអនាគត ។

គោលបំណងរបស់កម្មវិធីវិនិយោគសំរាប់ការអភិវឌ្ឍន៍ខេត្ត គឺជាការដកយកផ្នែកខ្លះដែលមានថវិកា ដោយផ្អែកលើការវិភាជន៍នៃប្រភពធនធានក្នុងចំណោមនៃសកម្មភាពអភិវឌ្ឍន៍ពីផែនកាអភិវឌ្ឍន៍ខេត្ត ។ បច្ចុប្បន្ននេះ កម្មវិធីវិនិយោគសំរាប់ការអភិវឌ្ឍន៍ខេត្តមានរយៈពេលតែពីរឆ្នាំប៉ុណ្ណោះ និងរយៈពេលនេះវាវែងជាងរយៈពេលនៃផែនការរួមបញ្ចូលគ្នារវាងរបស់មន្ទីរវិស័យបន្តិច ។ ការងារឥឡូវ គឺជាការបង្កើតផែនការបីឆ្នាំ ដោយយោងទៅតាមការណែនាំរបស់ក្រសួងផែនការ ក្នុងគោលបំណងរួមបញ្ចូលផែនការខេត្តដាក់ទៅក្នុងកម្មវិធីវិនិយោគសាធារណៈរបស់ជាតិ ។

បច្ចុប្បន្ននេះ កម្មវិធីវិនិយោគសំរាប់ការអភិវឌ្ឍន៍ខេត្តត្រូវបានប្រើប្រាស់ធ្វើជាកម្មវិធីវិនិយោគនោះ មានកំរិតកំណត់ ។ ថវិកាមួយផ្នែកតូចសំរាប់ការអភិវឌ្ឍន៍បានមកពីកម្មវិធីសិលា និងថវិកាមួយផ្នែកធំទៀតនោះគឺមានលក្ខណៈមិនច្បាស់លាស់ ។ នេះមានន័យថា កម្មវិធីវិនិយោគសំរាប់ការអភិវឌ្ឍន៍ខេត្ត ធ្វើឡើងដោយមានមូលនិធិប៉ាន់ស្មានច្រើនជាងមូលនិធិដែលបានបែងចែកច្បាស់លាស់សំរាប់ការសំរេចចិត្ត ឬការសន្យាពីដំបូងដែលត្រូវបានធ្វើឡើង ។ ទាំងនេះ វានៅតែជាករណីមិនច្បាស់លាស់រហូតទាល់តែដល់ពេលដែលរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយមានមូលនិធិ គ្រប់គ្រាប់ក្នុងការផ្តល់អោយ ។

មូលនិធិនៃផែនការវិនិយោគសិលាមានប្រសិទ្ធិភាពទៅលើ ថវិកាអភិវឌ្ឍន៍ប្រចាំឆ្នាំសំរាប់ខេត្ត ព្រោះខេត្តបានទទួលថវិកាពីប្រភពផ្សេងទៀតនោះវាតិចតួចណាស់សំរាប់គោលបំណងនេះ ។ នៅពេលដែលរដ្ឋាភិបាលមានលទ្ធភាពផ្តល់ថវិកអោយខេត្តបានច្រើនជាងនេះ នោះផែនការវិនិយោគសិលា នឹងក្លាយទៅជា កម្មវិធីវិនិយោគខេត្តដោយបញ្ចូលទាំងធនធានអភិវឌ្ឍន៍ដែលអាចមានទាំងអស់ ។

ចាប់តាំងពីខែ មិថុនា ១៩៩៩ ការទទួលខុសត្រូវក្នុងការគ្រប់គ្រងធនធានសិលា ត្រូវបានធ្វើការផ្ទេរពី ឃែរេរ អោយទៅអាជ្ញាធរខេត្ត ។ ដំណើរការកសាងផែនការខេត្ត មានបំណងផ្តល់ឱកាសអោយមន្ទីរជំនាញ និងភ្នាក់ងារផ្សេងទៀត មកចូលរួមក្នុងការសំរេចចិត្តចំពោះការទទួលខុសត្រូវនេះ និងជាពិសេសគឺការសំរេចចិត្តក្នុងការធ្វើវិភាជន៍ថវិកាសំរាប់មន្ទីរជំនាញ ។ រឿងនេះ វាពិបាកនឹងថាវាកើតឡើងបានពិតប្រាកដនៅក្នុងការអនុវត្តជាក់ស្តែង ។ បុគ្គលិកនៃមន្ទីរផែនការ និងគណៈកម្មាធិការប្រតិបត្តិខេត្ត បាននិយាយថាការសំរេចចិត្តនេះគឺឆ្លុះបញ្ចាំងពីការព្រមព្រៀងជាទូទៅ របស់មន្ទីរជំនាញ និងគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ប៉ុន្តែសមាជិកនៃក្រុមបេសកកម្មយើងខ្លះ នៅមានការការសង្ស័យក្នុងរឿងនេះ ។ គ្មានការសង្ស័យឡើយថាមន្ត្រីខ្លះនៅតែរក្សានូវទំលាប់ក្នុងការធ្វើផែនការពីលើចុះក្រោម និងធ្វើការសំរេចចិត្តតែម្នាក់ឯង ឬដោយគ្មានការចូលរួម ។ មានការកត់សំគាល់ដោយគំរនូវសារៈសំខាន់នៃការធ្វើអោយប្រាកដថា អ្នកដឹកនាំខេត្តត្រូវបានរាប់បញ្ចូលក្នុងការខិតខំប្រឹងប្រែងពង្រឹងសមត្ថភាព ដើម្បីផ្លាស់ប្តូរឥរិយាបទ និងការយល់ដឹងពីតួនាទីការងាររបស់ខ្លួន ។

ផ្នែកខ្លះមានលក្ខណៈកាន់តែច្បាស់ ។ ការផ្តល់មូលនិធិដោយឥតលក្ខខណ្ឌ ដោយសិលាអោយទៅខេត្តនិមួយៗ បានធ្វើអោយរដ្ឋបាលខេត្ត (តាមរយៈ គណៈកម្មាធិការអភិវឌ្ឍន៍ជមបទខេត្ត និងប្រត្តបត្តិខេត្ត ) ចាប់ផ្តើមក្នុងការរៀបចំធ្វើផែនការធ្វើការវិភាជន៍ធនធានទាំងនោះ ។ មន្ទីរជំនាញគេអាចផ្តើមគំនិតធ្វើសំណើរ ឬគំរោងផែនការរបស់គេ ប្រសើរជាងការគ្រាន់តែអនុវត្តតាមផែនការដែលបានរៀបចំដោយក្រសួងនៅថ្នាក់ជាតិ ។ ត្បិតតែដំណើការកសាងផែនការទើបតែចាប់ផ្តើមកើតឡើងក៏ដោយ ក៏ការងារនេះបានជួយសំរបសំរួលយ៉ាងធំធេងក្នុងការងារសហការរវាងមន្ទីរជំនាញទាំងឡាយនៅក្នុងខេត្ត និងធ្វើអោយមានលទ្ធភាពក្នុងការធ្វើការឆ្ពោះទៅកាន់គោលដៅរួម ។ ដូចគ្នានេះដែរ ការរៀបចំផែនការអភិវឌ្ឍន៍ឃុំ និងសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក ធ្វើអោយមន្ទីរជំនាញមានសន្ទុះក្នុងការទទួលខុសត្រូវទៅនិងសេចក្តីត្រូវការ និងតម្រូវការនៅថ្នាក់មូលដ្ឋានកាន់តែខ្លាំងឡើង ។ យើងសូមផ្តល់អនុសាសន៍ថា ផ្នែកទាំងអស់នេះត្រូវតែរក្សាទុក និងត្រូវតែបានពង្រឹងឡើង ។

ឃ- <u>ការងារតួនាទីបុរស និងស្ត្រី</u>

ការទទួលខុសត្រូវក្នុងការបញ្ចូលការងារតួនាទីបុរស-ស្ត្រី ក្រោមកម្មវិធីសិលានៅថ្នាក់ជាតិ គឺត្រូវបានផ្តល់អោយ ក្រសួងកិច្ចការនារី និងយុទ្ធជនពិការ ។ ក្រសួងនេះគឺជាសមាជិកនៃក្រុមដឹកនាំការងារសិលាមួយដែរ ដូច្នេះគេមានសកម្មភាព ដូចជាទីប្រឹក្សាដល់ក្រុមដឹកនាំសិលាចំពោះការងារដែលទាក់ទងទៅនិងកិច្ចការនារី ។ នៅថ្នាក់ខេត្ត មន្ទីរកិច្ចការនារី និងយុទ្ធជនពិការ ជាអ្នកតំណាងនៅក្នុងគណៈកម្មាធិការអភិវឌ្ឍន៍ជនបទ និងគណៈកម្មាធិការប្រត្តបត្តិខេត្ត ។ មន្ទីរនេះគឺជាអ្នកទទួលខុសត្រូវក្នុងការងារតួនាទីបុរស-ស្ត្រី នៅថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន ។

មន្ទីរនេះ ជាអ្នកដើរតួរសំខាន់នៅក្នុងគោលនយោបាយ និងដំណើរការធ្វើផែនការ ព្រមទាំងផ្តល់នូវព័ត៌មាន និងចំណេះដឹងអំពីតួរនាទីបុរស-ស្ត្រី តាមរយៈជនបង្គោលដែលមាននៅតាមមន្ទីរជំនាញ និងក្នុងរចនាសម្ព័ន្ធអភិវឌ្ឍន៍ជនបទរបស់កម្មវិធីសិលា ។

គោលបំណងគន្លឹះដែលទាក់ទងទៅនិងតួរនាទីបុរសស្ត្រីនេះ គឺ : ការបង្កើតចំណេះដឹងអំពីតួនាទី បុរស-ស្ត្រីនៅគ្រប់លំដាប់ថ្នាក់ទាំងអស់ ការពង្រឹងសមត្ថភាពជនបង្គោលរបស់ផ្នែកនេះដែលមាននៅក្នុងកម្មវិធីសិលា និងផ្តល់ឱកាសដល់ស្ត្រី និងពង្រឹងសមត្ថភាពពួកគេដើម្បីធ្វើការចូលរួមប្រកបដោយប្រសិទ្ធភាព ចំពោះភាពសមភាពនៅក្នុងរចនាសម្ព័ន្ធមូលដ្ឋាន និងក្នុងដំណើការកសាងផែនការមូលដ្ឋាន ។ ការពង្រឹងសមត្ថភាពរបស់បុគ្គលិកនៃមន្ទីរកិច្ចការនារី ត្រូវបានអនុវត្ត និងគាំទ្រដោយឃែរេរេ ។

ទោះបីមានចំនុំដែលត្រូវធ្វើការកែលំអរ និងដំណើរការបន្តទៀតក៏ដោយ ក៏សមិទ្ធិផលដែលសំរេចបានដោយសារដំណើរការផ្តល់ចំណេះដឹងផ្នែកតួរនាទីបុរស-ស្ត្រីនៅក្នុងខេត្តកម្មវិធីសិលា ទទួលបានគួរជាទីកត់សំគាល់ ។ បញ្ហាតួរនាទីបុរស-ស្ត្រីត្រូវបានឆ្លុះបញ្ចាំងអោយឃើញនៅជួរគណៈកម្មការអភិវឌ្ឍន៍ភូមិ និងឃុំ និងនៅក្នុងផែនការអភិវឌ្ឍន៍របស់មន្ទីរជំនាញ ។ ទិន្នន័យមូលដ្ឋានដែលមានលក្ខណៈញែកគ្នារវាងបុរស និងស្ត្រី ធ្វើឡើងដូចជាប្រពន្ធ័របាយការណ៍ ដែលទាក់ទិនទៅនិងការចូលរួម និងការទទួលផលប្រយោជន៍ ។ វត្តមានរបស់ជនបង្គោលក្នុងរចនាសម្ព័ន្ធកម្មវិធីសិលាតាំងពីថ្នាក់ជាតិរហូតដល់មូលដ្ឋាន បានជួយសំរបសំរួលក្នុងការពិភាក្សាអំពីបញ្ហាតួរនាទីបុរសស្ត្រី និងឆ្លើយតបទៅនិងបញ្ហាជាក់ស្តែង និងតម្រូវការជាយុទ្ធសាស្ត្ររបស់តួរនាទីបុរស-ស្ត្រី ។ នៅគ្រប់ដំណើរការកសាងផែនការមូលដ្ឋាន គឺមានកំរិតនៃការចូលរួមរបស់ស្ត្រីខ្ពស់ និងស្ត្រីបានមានឱកាសក្នុងការកំណត់ និងបញ្ចេញសំលេងរបស់ខ្លួនចំពោះបញ្ហាតម្រូវការរបស់ពួកគេ ។ ការខិតខំប្រឹងប្រែងក្នុងអំឡុងពេលនៃកម្មវិធីសិលាដើម្បីបង្កើនចំណេះដឹងអំពីតួនាទីបុរស-ស្ត្រី ទាំងក្នុងការធ្វើផែនការ និងកាគ្រប់គ្រងនៅក្នុងមន្ទីរជំនាញ និងនៅថ្នាក់មូលដ្ឋានជាមួយគណៈកម្មការអភិវឌ្ឍន៍ភូមិ ឃុំ និងសហគមន៍ជាច្រើន បានធ្វើអោយមានការផ្លាស់ប្តូរនូវចរិកលក្ខណៈយ៉ាងច្រើនគួរអោយកត់សំគាល់នៅគ្រប់លំដាប់ថ្នាក់ទាំងអស់ ។

យុទ្ធសាស្ត្ររបស់ការងារតួរនាទី បុរស-ស្ត្រី នៃកម្មវិធីសិលាបានពង្រឹងនូវស្ថានភាពសេដ្ឋកិច្ចនយោបានរបស់ស្ត្រី ។ ក្នុងគណៈកម្មការអភិវឌ្ឍន៍ភូមិបច្ចុប្បន្ន យ៉ាងហោចណាស់ក៏បានបញ្ចូលសមាជិកស្ត្រីពីរនាក់ដែរក្នុងចំណោមសមាជិកទាំងអស់ ៥ នាក់ ។ នៅខេត្តសៀមរាប មានស្ត្រីប្រាំបួននាក់ (១៨ ភាគរយ) បានទទួលតំនែងជាអ្នកដឹកនាំឃុំ ។ ការទទួលជោគជ័យជាវិជ្ជមាននេះក្នុងរយៈពេលមួយដ៏ខ្លីប៉ុណ្ណោះ ហើយនេះក៏ជាសញ្ញាមួយជាវិជ្ជមានក្នុងការសំរេចដល់តម្រូវការជាយុទ្ធសាស្ត្រនៃការងារតួរនាទីបុរស-ស្ត្រី ។

ទោះបីមានការរីកចំរើនក្នុងការងារសមាហរណកម្មតួនាទីបុរសស្ត្រី និងការផ្លាស់ប្តូរចរិកលក្ខណៈក្នុងកម្មវិធីសិលានេះក៏ដោយ ក៏នៅមានបញ្ហា និងតម្រូវការមួយចំនួនដែលត្រូវបានលើកឡើងដែរ ។ ការងារតួនាទី បុរស់ស្ត្រីនេះត្រូវបានមើលឃើញថាជាការទទួលខុសត្រូវរបស់មន្ទីរកិច្ចការនារី ។ ទោះជាយ៉ាងណេក សមត្ថភាព និងឥទ្ធិពលរបស់ក្រសួង មន្ទីរកិច្ចកានារី មានកំរិត ។ ហេតុនេះហើយ បានជាទំហំដែលវាអាចជះឥទ្ធិពលលើ និងជួយគាំទ្រទៅក្នុងគោលបំនងរបស់កម្មវិធីសិលា ក៏មានកំរិតដែរ ។ វាហាក់ដូចជាមានភាពមិនច្បាស់លាស់នៃចំពោះលក្ខខណ្ឌការងារដើម្បីធ្វើសមាហរណកម្មរយៈពេលយូរអង្វែងនៃការងារតួនាទីបុរស-ស្ត្រី ។ អន្តរាគមន៍នាពេលបច្ចុប្បន្ន គឺនៅសល់ការផ្តោតអារម្មណ៍យ៉ាងធំធេងទៅលើសកម្មភាពបណ្តុះបណ្តាល ដើម្បីបង្កើនចំណេះដឹងអំពីតួនាទីបុរស-ស្ត្រី ។ ទោះបីជា មានជនបង្គោលសំរាប់ការងារតួនាទីបុរស-ស្ត្រីជាច្រើននៅក្នុងគ្រប់លំថ្នាក់នៃរចនាសម្ព័ន្ធសិលាក៏ដោយ ក៏មួយចំនួនធំនៃអ្នកទាំងនោះមិនមែនជាអ្នក ដែលស្ថិតនៅក្នុងតួនាទីជាអ្នកមានឥទ្ធិពលក្នុងស្ថាប័ននោះឡើយ ។ ហេតុនេះហើយ ជារឿយៗ វាធ្វើអោយមានការលំបាកក្នុងការជំរុញការផ្សព្វផ្សាយចំណេះដឹងតួនាទីបុរស-ស្ត្រី និងយុទ្ធសាស្ត្រ របស់ខ្លួនអោយមានការឆ្ពោះទៅមុខ ។ ម្យ៉ាងទៀត ជនបង្គោលខ្លះខ្វះការជឿរជាក់លើខ្លួនឯង និងត្រូវការការពង្រឹង សមត្ថភាពបន្ថែម និងការគាំទ្របន្ថែមទៀត ។

ង- <u>រចនាសម្ព័ន្ធនៃការគ្រប់គ្រង</u>

នាពេលបច្ចុប្បន្ននេះ យ៉ែររេនៅតែរក្សានូវតួនាទីក្នុងការគ្រប់គ្រង និងដឹកនាំកម្មវិធីសិលា ។ នៅថ្នាក់ខេត្ត មុខងារគ្រប់គ្រងមួយភាគធំត្រូវបានផ្ទេរអោយទៅគណៈកម្មការប្រតិបត្តិ ។ ប៉ុន្តែក្រុមបុគ្គលិកផ្នែកពង្រឹងសមត្ថភាពមូលដ្ឋានរបស់យ៉ែររេនៅតែផ្តល់ការគាំទ្រយ៉ាងខ្លាំងទៅលើអ្នកសំរបសំរួលខេត្តស្រុក ។ នៅថ្នាក់ជាតិ ក្រុមដឹកនាំការងារសិលាទទួលខុសត្រូវលើការបង្កើតគោលនយោបាយ ។ ប៉ុន្តែពឹងផ្អែកយ៉ាងខ្លាំងទៅលើការណែនាំរបស់យ៉ែររេ ។ យ៉ែររេក៏ ទទួលខុសត្រូវក្នុងការគ្រប់គ្រងកម្មវិធីសិលាថ្នាក់ជាតិ និងផ្តល់នូវទំនាក់ទំនងយ៉ាងចាំបាច់រវាងអាជ្ញាធរថ្នាក់ខេត្ត និងរដ្ឋាភិបាលថ្នាក់ជាតិ ។ ក្នុងខណៈ ដែលមានការរីកចំរើនគួរអោយកត់សំគាល់នៅថ្នាក់ខេត្ត តែការរីកចំរើននេះ ក៏មិនអាចនិយាយបានចំពោះនៅថ្នាក់ជាតិដែរ ។

នៅលើទិដ្ឋភាពនៃគំនិតផ្តួចផ្តើម ដើម្បីកែទំរង់រដ្ឋបាលរបស់រាជរដ្ឋាភិបាលកម្ពុជាលើគោលនយោបាយវិមជ្ឈការ និងសហវិមជ្ឈការ យើងសូមផ្តល់អនុសាសន៍ថា គួរតែអនុវត្តនូវវិធានការដើម្បីពង្រឹងការខិតខំប្រឹងប្រែងនៃការពង្រឹងសមត្ថភាពនៅថ្នាក់ជាតិ និង ដើម្បីបញ្ចូលតួនាទីការងាររបស់យ៉ែររេ ទៅក្នុងរចនាសម្ព័ន្ធរដ្ឋាភិបាល ។ មានបីចំនុនដែលត្រូវធ្វើការពិចារណា គឺ : ការបង្កើតគោលនយោបាយ ការគ្រប់គ្រងកម្មវិធី និងប្រឹក្សាគាំទ្រ ។

ការបង្កើតគោលនយោបាយ : នៅថ្នាក់ជាតិ ការទទួលខុសត្រូវលើការបង្កើតគោលនយោបាយតាមបែបវិមជ្ឈការ និងសហវិមជ្ឈការមានសភាពមិនទាន់ច្បាស់លាស់ និងនៅមានការប្រែប្រួលនៅឡើយ ។ មួយផ្នែកនៃក្រុមដឹកនាំការងារសិលា ជាអ្នកដើរតួរសំខាន់ដែលមានការពាក់ពន្ធ័ក្នុងរឿងនេះ គឺក្រុមប្រឹក្សាដែលមានស្រាប់សំរាប់ការកែទំរង់រដ្ឋបាល ក្រុមប្រឹក្សាជាតិសំរាប់គាំទ្រដល់ក្រុមប្រឹក្សាឃុំ ដែលជាអ្នកគ្រោងគិតអំពីច្បាប់រដ្ឋបាលឃុំ និងក្រសួងមហាផ្ទៃ ក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ អង្គភាពនិមួយៗជាអ្នកទទួលខុសត្រូវលើប្រការដោយឡែកផ្សេងៗគ្នា ប៉ុន្តែតួរនាទីរបស់ពួកគេមានការជាន់គ្នា ឬត្រួតស៊ីគ្នា និងគ្មានអង្គភាពមួយណាដែលទទួលបន្ទុក និងសំរសំរួលការងាររួមទាំងមូលឡើយ ។ នៅមិនទាន់ដឹងច្បាស់ថាតើក្រសួងណាមួយជាអ្នកតំណាងអោយក្រុមប្រឹក្សាជាតិសំរាប់គាំទ្រដល់ក្រុមប្រឹក្សាឃុំ ។ ប៉ុន្តែវាហាក់ដូចជាបានបញ្ចូលអង្គភាពទាំងនោះជាច្រើនដើម្បីតំណាងអោយក្រុមដឹកនាំការងារសិលា និង ក្រុមប្រឹក្សាសំរាប់កែទំរង់រដ្ឋបាល និងមានអ្នកតំណាងខ្លះអាចជាមនុស្សតែមួយ ។

នៅពេលពីរ បីខែខាងមុខនេះ គេសង្ឃឹមថាច្បាប់រដ្ឋបាលឃុំនឹងត្រូវបានអនុម័ត ក្រុមប្រឹក្សាជាតិសំរាប់គាំទ្រដល់ក្រុមប្រឹក្សាឃុំត្រូវបានបង្កើត និងសេចក្តីណែនាំថ្មី អំពីវិមជ្ឈការនឹងត្រូវចេញប្រកាស ។ ទាំងនេះប្រហែលជាធ្វើអោយមានការប្រែប្រួលដល់ក្រុមដឹកនាំការងារសិលា ។ ទៅតាមអ្វីដែលអាចគិតឃើញនោះគឺប្រហែលជាមានរៀបចំនូវការទទួលខុសត្រូវថ្មី និងប្តូរតួរនាទីឡើងវិញ ឬក៏អាចបញ្ចូលអង្គភាពណាមួយជាមួយគ្នា ។

ទោះជាយ៉ាងណាក៏ដោយ ក៏យើងជំរុញអ្នកទាំងនេះអោយចូលរួមពាក់ពន្ធ័ជាមួយនិងការរៀបចំបង្កើតកម្មវិធីបន្ទាប់ ដោយមិនអោយមានការកង្វល់ខ្លាំងហួសហេតុពេកជាមួយនិងបញ្ហា ដែលថាតើអ្នកណាជាអ្នកទទួលខុសត្រូវលើកម្មវិធីសិលា ។ កម្មវិធី និងគោលគំនិតរបស់វា គឺអាចផ្លាស់ប្តូរបាន ។ តែអ្វីដែលជាបញ្ហាសំខាន់នោះគឺការធានាថាតើគោលគំនិតនេះត្រូវបានថែរក្សា និងយល់ដឹងយ៉ាងច្បាស់ដោយអ្នកដែលទទួលបន្ទុកកម្មវិធីនេះ ។

ដោយនិយាយដូច្នោះ យើងសូមផ្តល់អនុសាសន៍ថា អង្គភាពបង្កើតគោលនយោបាយត្រូវតែបានពង្រឹងអោយបានខ្លាំង ។ អង្គភាពនេះត្រូវតែមានអណត្តិច្បាស់លាស់ និងការទទួសខុសត្រូវក្នុងការធ្វើសេចក្តីសំរេចចិត្ត និងត្រូវតែមានការគាំទ្រដោយលេខាធិការដ្ឋានប្រតិបត្តិ ដើម្បីអោយគេអាចអនុវត្តនូវបេសកកម្មរបស់គេប្រកបដោយប្រសិទ្ធភាព ។ យោងទៅតាមទំហំនៃសកម្មភាពថ្នាក់ខេត្ត និងសេចក្តីត្រូវការដើម្បីបង្កើតការគាំទ្រដ៏ទូលំទូលាយនៅថ្នាក់ជាតិ វាប្រហែលជាត្រូវមានការប្រុងប្រយត្ន័ក្នុងការពង្រីកសមាសភាពនៃអង្គភាពបង្កើតគោលនយោបាយ ដោយបញ្ចូលក្រសួងសំខាន់ៗផ្សេងទៀតដែលទាក់ទិនទៅនិងការអភិវឌ្ឍន៍ និងជាពិសេសគឺអ្នកតំណាងមកពីខេត្តដែលមានកម្មវិធីសិលា ។

នៅថ្នាក់ខេត្ត ការរៀបចំគោលនយោបាយគឺស្ថិតនៅក្នុងកណ្តាប់ដៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ហើយមានការលេចធ្លោឡើងនូវការបំពេញការងារគួរជាទីពេញចិត្ត ។

<u>ការគ្រប់គ្រងកម្មវិធី</u> : សំរាប់ថ្នាក់ជាតិ យើងសូមផ្តល់អនុសាសន៍ថា ការទទួលខុសត្រូវក្នុងការគ្រប់គ្រងកម្មវិធី សិលា គួរតែផ្ទេរពី ឃែ.រ.រ ហើយបញ្ចូលទៅរដ្ឋាភិបាល ដែលជាលេខាធិការប្រតិបត្តិអង្គភាពគ្រប់គ្រងកម្មវិធីថ្នាក់ជាតិ ឬក៏ អ្វីស្រដៀងគ្នានេះ ។ តួនាទីសំខាន់នៃអង្គភាពនេះ គឺគាំទ្រដល់អង្គភាពរៀបចំគោលនយោបាយធ្វើការសំរេចចិត្ត គ្រប់គ្រងធនធានកម្មវិធី តាមដានការរីកចំរើន ផ្តល់ដំបូន្មានដល់ខេត្តនានា ហើយនិងគៀងគរធនធានបន្ថែមសំរាប់កម្មវិធី ។ យើងមើលឃើញអង្គភាពនេះស្រដៀងគ្នាទៅនឹងគណៈកម្មាធិការប្រតិបត្តិថ្នាក់ខេត្តដែរ ដោយមានការដឹកនាំពីក្រសួងសំខាន់ៗ និងបុគ្គលិកមានសមត្ថភាព ដែលត្រូវបានចាត់តាំងមកពីក្រសួងឱ្យមកធ្វើការពេញម៉ោង ។ អង្គភាពនឹងត្រូវមានទីតាំងល្អបំផុត ជាលក្ខណៈរដ្ឋបាលនៅក្រោមភ្នាក់ងារដឹកនាំអព្យាក្រិតមួយ ដែលមានសមត្ថភាពផ្តល់ការដឹកនាំ ហើយអាជ្ញាធររបស់ភ្នាក់ងារនេះត្រូវបានគេគោរពព្រមទាំងអាចធ្វើការសំរបសំរួលជាមួយក្រសួងដែលជាប់ពាក់ព័ន្ធ។ យើងសូមផ្តល់អនុសាសន៍ថា បុគ្គលិកភាគច្រើនត្រូវធ្វើការនៅកន្លែងជាមួយគ្នា ដើម្បីពួកគេអាចទំនាក់ទំនងគ្នាបានកាន់តែមានប្រសិទ្ធភាពព្រមទាំងកសាងបាននូវក្រុមការងាររឹងមាំ ប៉ុន្តែបុគ្គលិកមួយចំនួនទៀតអាចមានទីតាំងនៅពាក់កណ្តាល ឬពេញម៉ោងនៅតាមក្រសួងរបស់ខ្លួននិមួយៗ ទៅតាមការជាក់ស្តែង ។ អង្គភាព គួរតែត្រូវបានផ្តល់នូវថវិកាគ្រប់គ្រាន់ សំរាប់ទាក់ទាញបុគ្គលិកដែលមាន សមត្ថភាពឱ្យពួកគេចុះធ្វើការនៅតាម មូលដ្ឋានឱ្យបានញឹកញាប់ និងអនុវត្តការងារ របស់គេប្រកបដោយប្រសិទ្ធភាព ។

នៅថ្នាក់ខេត្ត តួនាទីគ្រប់គ្រងភាគច្រើនត្រូវបានផ្ទេរទៅឱ្យគណៈកម្មាធិការប្រតិបត្តិ រួចទៅហើយ ដែលគណៈកម្មាធិការនោះ រាយការណ៍ជូនទៅ គ.អ.ជ.ខ ។

<u>ការប្រឹក្សាគាំទ្រ</u> : គេនឹងត្រូវការ ក្រុមគាំទ្ររឹងពឹងមួយ សំរាប់ទាំងថ្នាក់ជាតិ និងថ្នាក់ខេត្ត ។ ភារកិច្ចសំខាន់ៗរបស់បុគ្គលិកគាំទ្រ នឹងប្រហាក់ប្រហែលគ្នាទៅនឹងភារកិច្ចដែលបុគ្គលិក ឃែ.រ.រ កំពុងអនុវត្តនាពេលបច្ចុប្បន្ន ច្រើនតែជាការងារពង្រឹងសមត្ថភាពដល់អង្គភាព និងបុគ្គលិកទាំងឡាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត តាមរយៈសិក្ខាសាលា ការធ្វើបណ្តើរ-រៀនបណ្តើរ ការធ្វើការជាមួយដៃគូសហការ ការរៀបចំដំណើរការការងារនីតិវិធី ឯកសារមេរៀន សេចក្តីណែនាំ និងគាំទ្រដល់អ្នកបង្កើតគោលនយោបាយ ។ នៅថ្នាក់ជាតិ ក្រុមគាំទ្រត្រូវនៅជាប់ជាមួយនឹងអង្គភាពគ្រប់គ្រងទើបជាការប្រសើរ តែនៅតាមបណ្តាខេត្ត សមាជិកអាចត្រូវបានបែងចែក ទៅតាមចំណុចយុទ្ធសាស្ត្រ ដែលពួកគេអាចអនុវត្តការងារប្រកបដោយប្រសិទ្ធភាព ។ កំរិតនៃការគាំទ្រដល់ថ្នាក់ខេត្ត

គួរតែស្រដៀងគ្នាទៅនឹងអ្វីដែលកំពុងផ្តល់នាពេលបច្ចុប្បន្ន ។ សមាជិកក្រុមគាំទ្រ នឹងត្រូវបានជ្រើសរើសពីក្នុងប្រទេស ហើយការគាំទ្រដោយបរទេស គួរតែកំណត់យកត្រឹមតែទីប្រឹក្សាប្រចាំតំបន់សំខាន់ៗ និងទីប្រឹក្សាធ្វើការរយៈពេលខ្លីមួយចំនួនទៀត ។

ច.- ត្រួតពិនិត្យ និងវាយតំលៃ

គំរោង /បួង់ និងកិច្ចប្រតិបត្តិការប្រកបដោយជោគជ័យ នៃប្រព័ន្ធត្រួតពិនិត្យ-វាយតំលៃ គឺមិនទាន់ប្រាកដនៅឡើយ ។ កម្មវិធី សិលាគ្មានការលើកលែងក្នុងផ្នែកនេះឡើយ ។ ហេតុនេះ វាពិបាកនឹងភ្ញាក់ផ្អើលថា ប្រព័ន្ធត្រួតពិនិត្យ-វាយតំលៃ ក្នុងកម្មវិធី សិលា ប្រហែលជាផ្នែកមួយដែលនៅខ្វះខាត និងមាននិរន្តរភាពតិចជាងគេក្នុងខ្លឹមសារនេះ ។ នៅខេត្តបាត់ដំបង មានសមាជិកត្រួតពិនិត្យ-វាយតំលៃដែលមិនមែនជាបុគ្គលិក យែ.រ.រ ចំនួន ១២ រូប ព្រមទាំងជនបង្គោលត្រួតពិនិត្យ-វាយតំលៃរបស់មន្ទីរជំនាញ បានធ្វើចំណាត់ថ្នាក់ទៅតាមសមត្ថភាពរបស់គេក្នុងការអនុវត្តន៍ ប្រព័ន្ធត្រួតពិនិត្យ-វាយតំលៃ ដោយគ្មានការគាំទ្រពីកម្មវិធី យែ.រ.រ ដោយកំណត់ពិន្ទុពី ១ ដល់ ១០ ( ពីងាយស្រួល ទៅលំបាក ) ហើយពិន្ទុជាមធ្យមគឺ ៧ ។

កាលពីឆ្នាំកន្លងមក ប្រព័ន្ធតាមដាន និងធ្វើរបាយការណ៍ថ្មីមួយទៀតត្រូវបានដេដាក់ឱ្យប្រើប្រាស់ តែប្រព័ន្ធនេះនៅតែមានគុណវិបត្តិ ។ ទិន្នន័យដ៏ច្រើនត្រូវបានប្រមូល និងរាយការណ៍ ( ប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ ) សំដៅលើសកម្មភាព និងលទ្ធផល ប៉ុន្តែមិនសូវសំដៅលើផ្នែកនិមួយៗឡើយ នេះមិនទាន់និយាយដល់គោលបំណងរបស់គំរោងផង ។ មិនសូវមានការតាមដានលើដំណើរការ និងឥទ្ធិពលឡើយ ។ ក្រៅពីនេះទិន្នន័យ និងពត៌មាននៅក្នុងរបាយការណ៍ ច្រើនតែជាការរៀបរាប់ មិនមែនជាលក្ខណៈវិភាគឡើយ ។ ក្នុងចំណុចបន្ទាប់នេះ យើងបានកត់សំគាល់ ថាមានការអនុវត្តន៍បានមួយកំរិត រហូតមកដល់ពេលនេះ ដោយជាទូទៅ របាយការណ៍រីកចំរើនបានបកស្រាយខ្លីៗនូវ បញ្ហាដែលបានជួបប្រទះ និងដំណោះស្រាយដែលស្នើឡើង ។

យើងចង់ដឹងអំពីសារប្រយោជន៍ សំរាប់គោលបំណងនៃការដឹកនាំ នៃពត៌មានមួយចំនួនដែលបានប្រមូលនាពេលបច្ចុប្បន្ន និងទទួលបាននូវចំឡើយដែលមិនទាន់ល្អ ចំពោះសំណួររបស់យើង ថាតើបរិមាណទិន្នន័យដ៏ស្មុចស្មើងនេះអាចយកមកប្រើប្រាស់បានយ៉ាងដូចម្តេចសំរាប់ជាឧបករណ៍របស់ថ្នាក់ដឹកនាំនោះ ។

និយាយដូចនេះ ដោយយើងដឹងថាកន្លងមក កម្មវិធី សិលា ត្រូវបានគេរិះគន់ពីម្ចាស់ជំនួយផងដែរ ដោយសារមានទិន្នន័យតិចតួចពេកអំពីសកម្មភាពទាំងនេះ ហើយយើងដឹងថាវាមានការលំបាកក្នុងការធ្វើឱ្យមានតុល្យភាព ។ នេះជាពេលដែលពិបាកក្នុងការស្នើឱ្យមានការកែប្រែជាថ្មីយ៉ាងច្រើន ទៅលើប្រព័ន្ធដែលកំពុង តែណែនាំឱ្យអនុវត្ត ក៏បន្ថែចំណុចមួយចំនួនគួរតែយកមកពិចារណាដែរ ។ បន្ទាន់បំផុតនោះគឺ ប្រព័ន្ធពត៌មានគួរតែ ផ្តោតទៅលើ

ថាតើអ្វីទៅដែលត្រូវការសំរាប់គោលបំណងនៃថ្នាក់ដឹកនាំ ដែលប្រហែលជាត្រូវកាត់បន្ថយបរិមាណពត៌មាន និងភាពញឹកញាប់នៃការប្រមូលពត៌មាន ព្រមទាំងផ្លាស់ប្តូរនូវមាតិកាមួយចំនួនរបស់ប្រព័ន្ធនេះ ។

ម្យ៉ាងទៀតយើងចាប់អារម្មណ៍ថា កម្មវិធី សិលា មានការថយចុះនូវក្តីរំពឹងដែលសមហេតុផល ចំពោះការងារត្រួតពិនិត្យ-វាយតំលៃ ហើយការងារនោះគឺការចងក្រងបទឯកសារបទពិសោធន៍ ដោយការសាកល្បង និងការរៀនសូត្រ ។ របាយការណ៍ និង ឯកសារមួយចំនួន ចងក្រងនូវលទ្ធផលដែលសំរេចបាន តែមិនសូវមានច្រើនទេ ហើយមិនសូវបាន កត់ត្រាអំពីវិធីសាស្ត្រ និងបទពិសោធន៍ដែលបានធ្វើការសាកល្បង ហើយបានបង្ហាញថាមិនសូវបានជោគជ័យនោះទេ ។ ដើម្បីជាការរៀនសូត្រ និងដើម្បីជាមធ្យោបាយពង្រឹងដល់ការចងចាំរបស់ស្ថាប័នផងនោះ ជាញឹកញាប់ចំណុចនេះ មានសារសំខាន់ដូចជាការចងក្រងនូវអ្វីដែលជាព្រឹត្តិការណ៍ទទួលបានជោគជ័យដែរ ។

កម្មវិធី សិលា បានទទួលការត្រួតពិនិត្យយ៉ាងល្អិតល្អន់ដោយក្រុម ដែលជួលដោយអង្គការ ស៊ីដា SIDA ។ យើង យល់ថាការងារនេះ បានផ្តល់ឱ្យ ឃែ.រ.រ និង កម្មវិធី សិលា នូវដៃគូពិភាក្សាដែលមានគុណភាពខ្ពស់ ។

កម្មវិធី សិលា បានទទួលការវាយតំលៃមួយចំនួន ដោយក្រុមវាយតំលៃខាងក្រៅ និងផ្ទៃក្នុង ហើយនិងទទួលការវាយតំលៃទាំងទៅលើកម្មវិធី សិលា ទាំងមូល (ការវាយតំលៃពាក់កណ្តាលគំរោង) ទាំងផ្នែកសំខាន់ៗ (ឧ:ការត្រួតពិនិត្យ-វាយតំលៃទៅលើដំណើរការកសាងផែនការមូលដ្ឋាន) ។ ទីបំផុត សកម្មភាពនៃការវាយតំលៃត្រូវបានគេគិតគូរ ហើយនិងមានគុណភាពខ្ពស់ ថែមទាំងបានរួមចំណែកយ៉ាងមានប្រយោជន៍ដល់ការវិវត្តន៍របស់គោលគំនិត និងកម្មវិធី សិលា ។

ឆ. <u>ភាពសមស្រប និងភាពអាចយកជាគំរូបាន នៃវិធីសាស្ត្រកសាងសមត្ថភាព</u>

តាមការចុះសង្កេតតាមមូលដ្ឋាន ជាទូទៅ បេសកកម្មឯកភាពជាមួយនិងសេចក្តីសន្និដ្ឋានរបស់អ្នកសង្កេតការកាលពីដើមដែលថា មានការរីកចំរើនយ៉ាងខ្លាំង ក្នុងការកសាងសមត្ថភាពនៅតាមបណ្តាខេត្តគោលដៅ ទោះជានៅមានចំណុចខ្លះត្រូវការពង្រីកបន្ថែមក៏ដោយ ជាពិសេសនៅថ្នាក់ឃុំ និងភូមិ ។ ទោះជាយ៉ាងណាក្តី មិនទាន់មានទិន្នន័យដើម ច្បាស់លាស់ណាមួយ សំរាប់យកមកធ្វើការផ្ទៀងផ្ទាត់ជាមួយគោលបំណងនៅឡើយទេ ។

ការកសាងសមត្ថភាព គឺជាផ្នែកសំខាន់ ក្នុងការគាំទ្ររបស់គំរោងឃែ.រ.រ ដល់កម្មវិធី ។ វាបង្កើតនូវភាពសមស្របដល់គំរោងគាំទ្រ ហើយនិងមានឥទ្ធិពលដល់សកម្មភាពស្ទើរតែទាំងអស់ ។ ជាដំបូង វិធីសាស្ត្រដែលមានលក្ខណៈទូលំទូលាយមួយ ត្រូវបានយកមកប្រើប្រាស់ សំដៅកសាងជំនាញបច្ចេកទេស និងជំនាញធ្វើផែនការនៅថ្នាក់ខេត្ត និងមន្ទីរជំនាញនានា ដោយដំណើរការស្របគ្នាជាមួយនឹងដំណើរការកសាងផែនការមូលដ្ឋាន ។ ក្នុង

អាណេត្តិនៃ ឃែ.រេ.រេ ២ វិធីសាស្ត្រនៃការកសាងសមត្ថភាពនេះ ត្រូវបានយកមកចំរាញ់ជ្រើសរើស និងធ្វើឱ្យសាមញ្ញ ព្រមទាំងបញ្ចូលគ្នាជាមួយនឹងវិធីសាស្ត្រក្នុងការសមាហរណកម្មការងារតួនាទីបុរស-ស្ត្រី ។

ការកសាងសមត្ថភាពសំរាប់ដំណើរការកសាងផែនការមូលដ្ឋាន រួមមានទាំងការផ្ទេរជំនាញក្នុងការគ្រប់គ្រង ការធ្វើផែនការ ហិរញ្ញកិច្ច និងការត្រួតពិនិត្យជូនដល់សហគមន៍ ។ នៅថ្នាក់មូលដ្ឋាន ការចូលរួមយ៉ាងសកម្ម និងភាពជាម្ចាស់ ត្រូវតែបានបង្កើតឡើង ដើម្បីធ្វើឱ្យដំណើរការមាននិរន្តរភាព និងជួយសំរបសំរួលការរួមចំណែករបស់សហគមន៍ និងការថែរក្សារបស់របរដែលត្រូវបានកសាងឡើង ។ កិច្ចការនេះ តម្រូវឱ្យមានការកែប្រែឥរិយាបទ និងការទទួលយកនូវតួនាទី ។ កម្មវិធីបង្ហាញនូវភាពជោគជ័យ ទាំងការជំរុញឱ្យមានការផ្លាស់ប្តូរឥរិយាបទ និងការបង្កើតបាននូវវិធីសាស្ត្រ និងនីតិវិធី ដែលច្បាស់លាស់ មានតម្លាភាព និង សមស្រប ដើម្បីអនុវត្តទៅលើគ្រប់ជំហាន និងយថាហេតុ ក្នុងដំណើរការនេះ ។

យ៉ាងណាមិញ តំលៃធនធានកន្លងមកឃើញថាគួរឱ្យកត់សំគាល់ ។ នៅក្នុងខេត្តទាំង ៥ ចំនួនបុគ្គលិក ឃែ.រេ.រេ ផ្នែកកសាងសមត្ថភាពមូលដ្ឋានសរុបមាន ៣៧ នាក់ គាំទ្រដល់បុគ្គលិកពង្រឹងសមត្ថភាពមូលដ្ឋានរបស់គណៈកម្មាធិការប្រតិបត្តិចំនួន ២៥២នាក់ ក្រុមសំរបសំរួលខេត្ត និងស្រុកចំនួន ១៧៤នាក់ និងបុគ្គលិកគាំទ្រផ្នែកបច្ចេកទេសចំនួន ៥០នាក់ ដែលជាមន្ត្រីរបស់រដ្ឋាភិបាល ដែលអនុវត្តការងារកសាងសមត្ថភាព ដែលទាក់ទងទៅនឹងដំណើរការកសាងផែនការមូលដ្ឋាន ។ បុគ្គលិក ឃែ.រេ.រេ ៧០នាក់ទៀត កំពុងតែធ្វើការជាមួយដៃគូក្នុងរចនាសម្ព័ន្ធកម្មវិធីសិលានិងមន្ទីរជំនាញនានា ដែលទាក់ទងទៅនឹងចំនុចដទៃៗទៀតនៃគោលគំនិត និងប្រព័ន្ធរបស់កម្មវិធី សិលា។

នៅថ្នាក់ខេត្ត ដោយធ្វើការតាមរយៈ គ.អ.ជ.ខ និង គណៈកម្មាធិការប្រតិបត្តិ ហើយនិងមន្ទីរជំនាញសំខាន់ៗ ដែលចូលរួម ការគាំទ្ររបស់កម្មវិធី ឃែ.រេ.រេ ធ្វើទៅលើការកសាងសមត្ថភាព ឥឡូវនេះផ្តោតទៅលើការគ្រប់គ្រងនៃប្រព័ន្ធធ្វើផែនការតាមបែបវិមជ្ឈការ ។ វាមានការបង្វែរទិសពីការផ្តល់ជំនាញបច្ចេកទេសដល់មន្ទីរជំនាញនានា ។

ក្នុងរាល់ការងារនេះ ការគាំទ្ររបស់ឃែ.រេ.រេ យ៉ាងខ្លាំងទៅលើការជំរុញលើកទឹកចិត្តដល់អ្នកចូលរួម និងផ្តល់បុគ្គលិកដើម្បីជួយផ្តល់ជំនាញ និងផ្តល់ថវិកាឧបត្ថម្ភលើកទឹកចិត្ត ដល់អ្នកដែលធ្វើការនៅក្រោមអង្គភាពកសាងសមត្ថភាពមូលដ្ឋាន ហើយសំខាន់ជាងគេនោះគឺធនធានទាំងឡាយ ដែលត្រូវការសំរាប់អ្នកអនុវត្តទាំងអស់ដើម្បីការរៀនសូត្រធ្វើបណ្តើរ ។

វិធីសាស្ត្រនៃការកសាងសមត្ថភាព ដូចដែលកំពុងបានអនុវត្តក្នុងកម្មវិធី សិលា ក្នុងខេត្តទាំង ៥ នាពេលបច្ចុប្បន្ននេះ បង្កើតឱ្យមានដំណើរការមួយដែលស៊ីសង្វាក់គ្នាល្អ និងមានលក្ខណៈយុទ្ធសាស្ត្រ ។ រហូតមកដល់ពេលនេះជាទូទៅ ដំណើរការនេះបានទទួលជោគជ័យ ហើយជាពិសេស មានការទាក់ទងទៅនឹងគោលនយោបាយរដ្ឋាភិបាលបច្ចុប្បន្ន ដែលផ្តោតទៅលើរបបវិមជ្ឈការ ចំពោះថ្នាក់ឃុំ ។ វិធីសាស្ត្រនៃការកសាងសមត្ថភាពបែបនេះ មានលក្ខណៈសមស្របដាច់គេសំរាប់យកជាគំរូដើម្បីអនុវត្តតាម ក្នុងការគាំទ្រដល់គោលគំនិតកម្មវិធី សិលា សំរាប់ខេត្តផ្សេងៗទៀត ។ ទោះជាយ៉ាងណាក៏ដោយ ការយកទៅអនុវត្តតាមបានដោយជោគជ័យ នឹងទាមទារនូវធនធានមនុស្ស និងថវិកា ច្រើនបង្គួរ ព្រមទាំងអាណត្តិមួយយ៉ាងជាក់លាក់ ។

<u>ភាពអាចអនុវត្ត ឬចំលងតាមបាន</u> ៖ ការយកទៅអនុវត្តតាមនៃកម្មវិធីសិលា ក្នុងខេត្តថ្មីៗទៀត នឹងទាមទារនូវការ កសាងសមត្ថភាព ដើម្បីស្វែងយល់គោលគំនិតនេះ ជាមួយនឹងអ្នកចូលរួមជាច្រើន រួមមានទាំងការផ្លាស់ប្តូរឥរិយាបទ និងការយល់ដឹងនៅគ្រប់ថ្នាក់នៃរដ្ឋាភិបាលទាំងនៅក្នុងសហគមន៍ ។ ការកសាងសមត្ថភាពនៅខេត្តថ្មីៗទៀត នឹងត្រូវអនុវត្តទៅតាម របៀបមួយយ៉ាងល្អិតល្អន់ ជាប្រព័ន្ធដែលមាននិរន្តរភាព ហើយនឹងគ្របដណ្តប់ទៅលើរចនាសម្ព័ន្ធថ្មី ប្រព័ន្ធធ្វើផែនការ និងនីតិវិធីនានា ។ បច្ចុប្បន្ន ក្រុមដឹកនាំការងារ សិលា ថ្នាក់ជាតិសង្ឃឹមថានឹងសំរេចបានការងារនេះ នៅតាមបណ្តាខេត្ត និងស្រុកទាំងអស់ ដែលបំរើការឱ្យឃុំសរុបចំនួន ១៤២៥ ឃុំ ក្នុងឆ្នាំ២០០៥ ។ ក្រុមបេសកកម្មវាយតំលៃយល់ឃើញថា នេះជាភារកិច្ចមួយដែលមានមហិច្ឆតាខ្ពស់ ប្រសិនបើគេត្រូវសំរេចឱ្យបានដោយគ្មានការយល់ស្របទៅលើគោលគំនិតនៃ កម្មវិធី សិលា ទេនោះ ។

<u>កត្តា និងឧបសគ្គផ្សេងៗ ដែលរាំងដល់ភារកិច្ច</u> ៖ ឧបសគ្គទីមួយ និងចំបងនោះ គឺធនធានមនុស្សដែលមាន និងអាចប្រើប្រាស់បាន ។ នៅពេលដែលពង្រាងក្របខ័ណ្ឌការងារកម្មវិធី មើលឃើញជាមុននូវការកាត់បន្ថយ ជាច្រើននូវតំរូវការធនធានមនុស្ស សំរាប់ការយកទៅអនុវត្តតាមនៃកម្មវិធីសាលា ។ បេសកកម្មវាយតំលៃមានចំងល់យ៉ាងខ្លាំងអំពីកំរិតនៃការកាត់បន្ថយក្នុងការគាំទ្រ និងកំរិតនៃការកាត់បន្ថយបុគ្គលិកប្រតិបត្តិការ ដោយពុំមានការថ្លឹងថ្លែងទៅលើការអនុវត្តន៍ ប្រកបដោយជោគជ័យ ទៅតាមគំនិតរបស់កម្មវិធី សិលា ទេនោះ។ យើងបារម្ភថាការកាត់បន្ថយបុគ្គលិកច្រើនពេកនឹងធ្វើឱ្យអន្តរាយដល់ការប្រឹងប្រែងក្នុងការផ្លាស់ប្តូរឥរិយាបទ និងការយល់ដឹងដែលបណ្តាល ឱ្យផ្នែកសំខាន់ៗនៃប្រព័ន្ធ ដូចជាដំណើរការកសាងផែនការមូលដ្ឋាន និងអាចធ្វើឱ្យសំរេចមិនបានទៅតាមនីតិវិធីរដ្ឋបាលដែលបានកំណត់ ។ បញ្ហានេះនឹងកាន់តែធ្វើឱ្យមានការព្រួយបារម្ភថែមទៀត ប្រសិនបើមានសម្ពាធ

ដើម្បីសំរេចឱ្យបានទៅតាមទំហំគ្រោងរបស់ថ្នាក់ជាតិ ក្នុងអាណត្តិមួយដែលមិនជាក់លាក់។ បន្ថែមលើផ្នែកនេះ គឺត្រូវការ ឱ្យមានការកសាងសមត្ថភាពដោយយកចិតទុកដាក់សំរាប់ថ្នាក់ជាតិ និងសំរាប់ក្រុមប្រឹក្សាឃុំថ្មី ។

កត្តាមួយទៀតដែលត្រូវយកចិត្តទុកដាក់គឺ ខេត្តថ្មីៗលែងដំណោងឱ្យកន្លែងដែលគ្មានការអភិវឌ្ឍន៍ ដូចកាលដំណាក់កាលកម្មវិធី ស៊ែ.រ.រ ជំហានទី១ និង ស៊ែ.រ.រ / សិលានោះឡើយ ។ ប្រព័ន្ធដែលបានបង្កើតឡើង និងរបៀបប្រតិបត្តិ មានរូបជាស្រេចទៅតាមករិត និងគោលការណ៍ផ្សេងៗ ។ ហើយធនធានទាំងឡាយក៏ត្រូវបានបង្ហាញហើយដែរ ទោះបីជាតាមរបៀប ពីខាងក្រៅ ឬស្រដៀងគ្នានិងប្រព័ន្ធរដ្ឋាភិបាលក៏ដោយ ។ ការសន្ទត់ក្នុងការបង្កើតអនុត្តរភាពនៃគំនិត និងវិធីសាស្ត្រក្នុងខេត្តថ្មីៗ អាចជាការធ្វើទៅតាមការអនុវត្តន៍របស់ស្ថាប័នដែលមានស្រាប់ និងការងារជាក់ស្តែង ផ្សេងៗទៀតជាមូលដ្ឋាន ។

ការកសាងសមត្ថភាពនៅថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន ត្រូវតែបំពេញឱ្យស្របទៅតាម ការកសាងសមត្ថភាពល្អិតល្អន់ នៅថ្នាក់ជាតិ ដោយផ្តោតទៅលើ សភាគោលនយោបាយ និងសភាប្រតិបត្តិ ដើម្បីឱ្យពួកគេអនុវត្តតួនាទី បានប្រកបដោយប្រសិទ្ធភាព ។ ស្រដៀងគ្នានេះដែរ ដើម្បីសំរេចឱ្យបាន នូវការប្រតិបត្តិតាមការព្រមព្រៀង ប្រកបដោយប្រសិទ្ធភាព ការកសាងសមត្ថភាព ដែលទាក់ទងទៅនឹង បញ្ហាកាត់ផ្តាច់ទំនាក់ទំនង ដូចជា តុល្យភាពបុរស និងស្ត្រី ( ជេនឌឺ ) គួរតែត្រូវបានអនុវត្តនៅក្នុងខេត្តថ្មី មុននឹងចាប់ផ្តើមអនុវត្តប្រព័ន្ធកម្មវិធី សិលា ។ បញ្ហាទាំងពីរនេះនឹងត្រូវការធនធានសំរាប់កសាងសមត្ថភាពបន្ថែមទៀត ។

<u>កត្តាដែលជួយសំរបសំរួលដល់កិច្ច</u>ការងារ : ទោះជាមានភាពមានករិត និងឧបសគ្គយ៉ាងច្បាស់មួយចំនួននៅក្នុងខេត្តថ្មីក៏ដោយក៏មានកត្តាផ្សេងៗទៀត ដែលអាចជួយដល់កិច្ចការងារក្នុងការអនុវត្តតាមនៃកម្មវិធីសិលា ។ នៅក្នុងជំហានបន្ទាប់ នឹងត្រូវការកែសំរួលបន្តិចបន្តួចប៉ុណ្ណោះទៅលើប្រព័ន្ធទាំងឡាយដែលបានបង្កើត រហូតមកដល់ពេលនេះ ដូចជាតំលៃថវិកា និងធនធានមនុស្សគួរឱ្យកត់សំគាល់ក្នុងខេត្តដែលមានកម្មវិធី សិលា ។ បើការកែសំរួល និងការកែតំរូវបន្ថែមទៅតាមបរិបទក្រុមប្រឹក្សាឃុំថ្មី ដែលអាចបញ្ចប់មុនការអនុវត្តនៅក្នុងខេត្តថ្មីនោះ វាធ្វើអោយ ដំណើរការ ប្រព័ន្ធ និងវិធីសាស្ត្រនៃកម្មវិធី សិលា នឹងមិនមានការកែប្រែអ្វីច្រើន ដូចដែលបានកើតឡើងនៅក្នុងជំហានធ្វើពិសោធន៍នោះឡើយ ។ ការប្តូរពីការធ្វើពិសោធន៍ មកជាការអនុវត្តតាម គឺជាភារៈកិច្ចមួយដែលកាន់តែសាមញ្ញ ។

គេអាចសន្និដ្ឋានថា បច្ចុប្បន្ន កំរិតជំនាញបច្ចេកទេសនៅតាមមន្ទីរជំនាញជាច្រើន នៅក្នុងខេត្តថ្មី មានកំរិតខ្ពស់ជាងច្រើន បើប្រៀបធៀបទៅនឹងករណី ដែលកម្មវិធី សិលា បានចាប់ផ្តើមការងារក្នុងខេត្តទាំង ៥ នោះ ។ ចំណុចនេះធ្វើឱ្យគេផ្តោតការប្រើប្រាស់ធនធានរបស់កម្មវិធី សិលា ទៅលើការកសាងសមត្ថភាពសំរាប់ការអនុវត្តតាមគោលគំនិតកម្មវិធី សិលា ដោយបន្ថយការផ្តល់ជំនួយបច្ចេកទេសដល់តាមបណ្តាមន្ទីរជំនាញ ។ ហើយអាចមានឱកាសដើម្បីធ្វើការជាមួយនឹងគំរោង និងកម្មវិធីផ្សេងៗទៀត ដែលបានគ្រោងទុកជាស្រេច ឬ មានស្រាប់នៅក្នុងខេត្តថ្មីផង។ ប្រសិនបើមានដូច្នេះ គេអាចផ្តោតការប្រើប្រាស់ធនធានរបស់កម្មវិធីទៅលើគោលបំណងនៃការកសាងសមត្ថភាព ដែលជាគន្លឹះនៃគោលគំនិតកម្មវិធី សិលា ។ នៅពេលដែលខេត្តថ្មីនិមួយៗ បង្ហាញនូវស្ថានភាពខុសៗគ្នា ទិន្នន័យដើមដែលមានការខ្វះខាត ដែលតែងតែជួបប្រទះ នៅពេលចាប់ផ្តើមដំណាក់កាលសព្វថ្ងៃនេះ ប្រហែលជានឹងមិនមានទេ ។ ដោយហេតុនេះ មុនពេលចូលអនុវត្តការងារក្នុងខេត្តថ្មី ចាំបាច់ត្រូវធ្វើការសិក្សា វិភាគទៅលើសមត្ថភាព និងតំរូវការឱ្យបានល្អិតល្អន់សិន។ ការងារនេះ គួររាប់បញ្ចូលទាំងការវិភាគទៅលើធនធានដែលមានសក្តានុពល ដែលអាចត្រូវបានគេប្រើប្រាស់ដើម្បីគាំទ្រដល់គោលបំណងរួម តាមរយៈដំណើរការសហការគ្នា ។ កម្មវិធីបច្ចុប្បន្ន មានមូលដ្ឋានធនធានមនុស្ស គួរឱ្យគត់សំគាល់នៅតាមបណ្តាខេត្តដែលមានកម្មវិធីសិលា ដែលធនធាននោះមាននៅក្នុងតួនាទីគាំទ្ររបស់ ឃៈរ.រ រដ្ឋាភិបាល និងរចនាសម្ព័ន្ធកម្មវិធីសិលា ព្រមទាំងនៅថ្នាក់សហគមន៍ផងដែរ។ ធនធានទាំងនេះអាចត្រូវបានគេយកមកប្រើប្រកប ដោយប្រសិទ្ធភាព ក្នុងដំណើរការ យកជាគំរូដើម្បីអនុវត្តតាម ។ ការណែនាំទស្សនៈកិច្ចសិក្សា នៅគ្រប់លំដាប់ថ្នាក់ ការផ្លាស់ប្តូរបុគ្គលិកពីខេត្តមួយទៅខេត្តមួយ និងការជំនួសការងាររយៈពេលខ្លីជាមួយនឹងការផ្លាស់ប្តូរទីកន្លែងតាមយុទ្ធសាស្ត្រ របស់បុគ្គលិកគាំទ្រ អាចរួមចំណែកយ៉ាងមានប្រសិទ្ធភាព ដល់ដំណើរការកសាងសមត្ថភាព ។

គេអាចសន្និដ្ឋានថា ការយកធ្វើជាគំរូ ដែលមានទ្រង់ទ្រាយធំ អាចកើតឡើង លុះត្រាតែមានអាជ្ញាធរ នៃគោលនយោបាយថ្នាក់ជាតិ ។ អាជ្ញាធរនេះ នឹងជួយយ៉ាងច្រើនដល់ការធ្វើសមាហរណកម្ម នៃកម្មវិធី ជាមួយនឹងប្រព័ន្ធរដ្ឋាភិបាលថ្នាក់ខេត្ត ។ លើសពីនេះទៀត នឹងមានមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់មួយចំនួន ដែលត្រូវបានចាត់តាំងពីខេត្តដែលមានកម្មវិធី សិលាឱ្យទៅកាន់ខេត្តគោលដៅថ្មី ។ មន្ត្រីដែលបានយល់ដឹងអំពីគោលគំនិតរបស់កម្មវិធី សិលា និងជួយគាំទ្រ ដល់កម្មវិធីនេះរួចមកហើយនោះ នឹងអាចជួយក្នុងការជំរុញដល់ការទទួលយកគំនិត និងដំណើរការកសាងសមត្ថភាព។

៣. មូលដ្ឋានរួមជាមួយនិងគំរោងដទៃទៀត

ក្រុមបេសកកម្មយើងពុំមានឱកាសដើម្បីសង្កេតមើលគំរោងផ្សេងៗ នៅក្រៅខេត្តដែលមានកម្មវិធី សិលា ឡើយ ។ ទោះជាយ៉ាងណាក៏ដោយ ការប្រជុំមួយត្រូវបានរៀបចំឡើងជាមួយនិង UNICEF, គំរោងរបស់ EC/PRASAC, GTZ, ហើយនិងគំរោងអភិវឌ្ឍន៍ភូមិនៅភូមិភាគឦសានដែលគាំទ្រដោយធនាគារពិភពលោក និង មូលនិធិសង្គមនៃប្រទេសកម្ពុជា ។ ឯកសារមួយចំនួនដែលរៀបរាប់អំពីគំរោងទាំងនេះ ក៏ត្រូវបានគេផ្តល់ឱ្យក្រុមបេសកកម្មយើងដែរ ។ ការប្រជុំដាច់ដោយឡែកៗក៏បានរៀបចំឡើងជាមួយនិងអង្គការ ស៊ីដា(SIDA), អង្គការ AusAID និងធនាគារពិភពលោក ។ ក្នុងដំណើរចុះទស្សនកិច្ចតាមមូលដ្ឋាន ក្រុមយើងក៏បានជួបជាមួយនិងបុគ្គលិកគំរោងមួយ ចំនួន ដូចជាបុគ្គលិកបច្ចេកទេសរបស់អង្គការ CAAEP, FAO និងបុគ្គលិកគាំទ្របច្ចេកទេសរបស់កម្មវិធី គាំទ្រកសិកម្មរបស់អង្គការ IFAD នៅក្នុងខេត្តប៉ៃលិន ។ ក៏មានការពិភាក្សាផងដែរជាមួយនិងបុគ្គលិកអង្គការ អន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលនៅក្នុងខេត្តទាំងនេះ ។

ការរកឃើញដ៏ច្បាស់លាស់របស់បេសកកម្មនេះគឺ គ្មានគំរោង ឬ កម្មវិធីណាមួយដែលមានគោលបំណងដូចកម្មវិធី សិលា ដែលបង្កើតឱ្យមានគំរូមួយសំរាប់កិច្ចអភិវឌ្ឍន៍តាមបែបវិមជ្ឈការ ដែលធ្វើឱ្យមានប្រព័ន្ធត្រឹមត្រូវ ក្នុងការទំនាក់ទំនង ជាមួយគ្រប់លំដាប់ថ្នាក់ និងអ្នកចូលរួមទាំងអស់នៅក្នុងខេត្ត ជាពិសេសគឺនៅថ្នាក់ឃុំ ហើយគ្មានកម្មវិធី ឬ គំរោងណាមួយ បានទទួលជោគជ័យក្នុងការបង្កើតឱ្យមានគំរូបែបនេះឡើយ ។

ដោយគ្មានដំណើរការនៃគំរូធ្វើផែនការអភិវឌ្ឍន៍តាមបែបវិមជ្ឈការនៅក្នុងខេត្តភាគច្រើន ភាពសំខាន់របស់ម្ចាស់ជំនួយ និងយុទ្ធសាស្ត្ររបស់គំរោង ជាទូទៅ បាននាំទៅរកការបង្កើតឱ្យមានបរិយាកាសប្រតិបត្តិការ ការងារដោយឯករាជ្យ ។ សំរាប់ផ្នែកភាគច្រើន គឺគំរោងផ្សេងៗដែលផ្តោតទៅលើវិស័យ ហាក់ដូចជា ជៀសវាងពីប្រព័ន្ធធ្វើផែនការ និងប្រព័ន្ធហិរញ្ញវត្ថុរបស់រដ្ឋាភិបាល ហើយនិងអនុវត្តតាមរយៈភ្នាក់ងារដែលជាខ្សែបណ្តោយពិសេសៗ ។ កន្លែងដែលបានបង្កើតឡើងនូវអន្តរៈភ្នាក់ងារ គឺក្នុងគោលបំណងជួយសំរួលដល់ការផ្តល់ធនធាន ជាជាងការពង្រឹងប្រព័ន្ធរបស់រដ្ឋាភិបាល ។ នៅពេលដែលគំរោងមួយចំនួន មានការយកចិត្តទុកដាក់ដោយមានការចូលរួមខ្ពស់ ដើម្បីគិតគូរលើបញ្ហា តំរូវការ ភាពជាម្ចាស់របស់មូលដ្ឋាន និងនិរន្តរភាព ។ ការចូលរួមបែបនេះ ផ្តោតជាបឋមទៅថ្នាក់ភូមិជាជាងថ្នាក់ឃុំ ហើយជំរុញឆ្ពោះទៅរកការផ្តល់ផលិតកម្ម និងសេវាកម្មជាក់លាក់ ។ យ៉ាងណាមិញ ក្នុងការពិភាក្សាជាមួយអ្នកតំណាងគំរោងផ្សេងៗទៀត ឃើញថា ពួកគេអាចបញ្ចូលនូវវិធីសាស្ត្រ និងបច្ចេកទេសមួយចំនួន ដែលកម្មវិធី សិលា អាចរៀនសូត្របាន ហើយដែលអាចសមស្របក្នុងការដាក់បញ្ចូលទៅក្នុងគំរូកម្មវិធី សិលា នៅក្នុងខេត្តថ្មី ឬ ក្នុងខេត្តចាស់។ ចំណុចទាំងនេះអាចយកទៅអនុវត្តសំរាប់សកម្មភាពសហគមន៍ ឬ ធ្វើការជាមួយភ្នាក់ងារនានា។

យើងសំណូមពរថា ត្រូវរកឱកាសសំរាប់ផ្លាស់ប្តូរគំនិតគ្នា រវាងវិធីសាស្ត្ររបស់កម្មវិធី សិលា និងគំរោងដទៃទៀត មុនពេលអនុវត្តតាមគំរូកម្មវិធី សិលា នៅក្នុងខេត្តថ្មី ដែលមានគំរោងនានាកំពុងដំណើរការហើយ ។

ស្ថាប័នម្ចាស់ជំនួយ និងអ្នកអនុវត្តគំរោង កាន់តែយល់ច្បាស់អំពីគំរូកម្មវិធី សិលា ពួកគេបានទទួលស្គាល់នូវភាពជាប់ពាក់ព័ន្ធ និងការប្រើប្រាស់ប្រកបដោយសក្តានុពល របស់កម្មវិធី ក្នុងការផ្តល់នូវប្រព័ន្ធដែលបង្កើតហើយស្រាប់ និងស្ថាប័នមូលដ្ឋានទាំងឡាយសំរាប់ការផ្តល់ធនធានតាមបែបវិមជ្ឈការ ។ ការផ្តល់នេះមានទំរង់បែបបទជាច្រើន ដូចជា : អង្គការ IFAD គាំទ្រវិស័យកសិកម្ម នៅក្នុងខេត្តផ្ទៃកនិរតី ការគាំទ្រដោយទ្វេភាគីសំរាប់កម្មវិធីបង្រួបបង្រួម ពីម្ចាស់ជំនួយមួយចំនួន រួមមានទាំង ធនាគារពិភពលោក និងអង្គការ AusAID ហើយនិងកិច្ចសហការដ៏ល្អជាមួយនិងអង្គការក្រៅរដ្ឋាភិបាល នៅក្នុងខេត្តដែលមានកម្មវិធី សិលា ជាពិសេសក្នុងការជួយគាំទ្រដល់សហគមន៍មូលដ្ឋាន ។

ការអនុវត្តន៍តាមគំរូកម្មវិធី សិលា នៅក្នុងខេត្តផ្សេងៗទៀត ផ្តល់នូវក្របខ័ណ្ឌការងារដ៏មានសក្តានុពល សំរាប់កម្មវិធីថ្មី និងកម្មវិធីដែលមានស្រាប់ ដើម្បីរួមចំណែកឱ្យកាន់តែច្រើនក្នុងការពង្រឹងរបបវិមជ្ឈការ និងភាពជាម្ចាស់របស់ជាតិទៅលើដំណើរការអភិវឌ្ឍន៍ ។ យើងសំណូមពរថា មុននឹងចូលទៅអនុវត្តការងារនៅក្នុងខេត្តថ្មី កម្មវិធី សិលា គួរតែរិះរកឱកាសសំរាប់ផ្លាស់ប្តូរគំនិតគ្នាឱ្យបានច្រើន និងធ្វើឱ្យវិធីសាស្ត្រទាំងឡាយ ស្របគ្នា និងស៊ីសង្វាក់គ្នា។

៤. ភាពជាប់ពាក់ព័ន្ធ

គេបានសូមឱ្យក្រុមបេសកកម្ម វាយតំលៃទៅលើចំណុចខ្លាំង និងចំណុចខ្សោយនៃគំរូកម្មវិធី សិលា ក្នុងបរិបទ នៃការប្រឹងប្រែងរបស់រាជរដ្ឋាភិបាលដែលកំពុងដំណើរការឆ្ពោះទៅរកការកែទំរង់រដ្ឋ និងដំណើរការប្រជាធិបតេយ្យ ជាពិសេសគឺ របបវិមជ្ឈការ និងការកែទំរង់រដ្ឋបាលសាធារណៈ ។

ដូចដែលគេបានដឹងយ៉ាងច្បាស់ កម្មវិធី ស៊ែ.រ.រ-២ / សិលា ខ្លួនឯងគឺជាសារធាតុជំរុញ (កាតាលីករ) ដែលជំរុញឱ្យមានចំណាប់អារម្មណ៍ជាសាធារណៈ និងការនាំឱ្យគោលនយោបាយបច្ចុប្បន្ន របស់រដ្ឋាភិបាល តម្រង់ឆ្ពោះទៅរករបបវិមជ្ឈការ ។ កម្មវិធី សំរេចកិច្ចការនេះបាន ដោយសារការបង្កើតនូវគំរូមួយ សំរាប់ការធ្វើផែនការ និងការអភិវឌ្ឍន៍រួមគ្នាសំរាប់ឃុំ និងខេត្ត ហើយនិងបង្ហាញថាការងារនេះមានប្រសិទ្ធភាព ។

ក្នុងន័យវិមជ្ឈការ និងការបង្កើតនូវក្រុមប្រឹក្សាឃុំ ដែលមាននៅក្នុងច្បាប់រដ្ឋបាលឃុំ កម្មវិធី សិលា ផ្តល់នូវយន្តការ ជាពិសេស ដែលជួយដល់ការកសាងសមត្ថភាពនៅថ្នាក់ឃុំ និងភូមិ ។ ការកសាងសមត្ថភាពនេះ រាប់បញ្ចូលទាំងដំណើរការកសាងផែនការមូលដ្ឋាន ដើម្បីបង្កើតឱ្យមាន សំណើរដែលរៀបចំដោយសហគមន៍ វិធីសាស្ត្រសំរាប់ធ្វើផែនការដោយសហគមន៍ ការសំរេចចិត្ត ការរៀបចំកិច្ចសន្យា ការអនុវត្តន៍ និងការចាត់ចែងហិរញ្ញវត្ថុ ។ និងទុន

អភិវឌ្ឍន៍មូលដ្ឋានត្រូវបានរៀបចំឡើង ដើម្បីបែងចែកធនធានពីរដ្ឋាភិបាល និងម្ចាស់ជំនួយ ទៅដល់ឃុំ សំរាប់សកម្មភាពអភិវឌ្ឍន៍ ។ នៅពេលដែលគេអាចកែតំរូវដោយងាយស្រួល នូវយន្តការទាំងអស់នេះ ដើម្បីជួយដល់ការបង្កើតក្រុមប្រឹក្សាថ្នាក់ឃុំហើយ កម្មវិធី សិលា មិនផ្តល់នូវចំណេះដឹង បទពិសោធន៍ ឬជំនាញអ្វីដែលត្រូវការសំរាប់រៀបចំបង្កើតក្រុមប្រឹក្សាឃុំ និងកសាងសមត្ថភាពក្នុងរដ្ឋបាលឃុំឡើយ ។

ក្នុងន័យសហវិមជ្ឈការរបស់រដ្ឋាភិបាលពីថ្នាក់ជាតិ ទៅថ្នាក់ខេត្ត កម្មវិធីសិលាបានបង្កើតរួចជាស្រេចនូវយន្តការដែលរំពឹងថានឹងផ្ទេរតួនាទី និងធនធានទាំងឡាយឱ្យទៅរដ្ឋបាលថ្នាក់ខេត្ត ។ យន្តការទាំងនេះ រួមមានដំណើរការ នៃការធ្វើផែនការអន្តរវិស័យ និងការបែងចែកធនធាន ការផ្តល់ទុនដោយបើកទូលាយ ដើម្បីឱ្យមន្ទីរអាចបង្កើតនូវ ការផ្តួចផ្តើម គំនិត ប្រព័ន្ធសំរាប់គ្រប់គ្រងធនធាន និងការត្រួតពិនិត្យថវិកា និងបច្ចេកទេសសំរាប់ពង្រឹងសមត្ថភាពមន្ទីរជំនាញនានា អង្គភាពទាំងឡាយរបស់គណៈកម្មាធិការប្រតិបត្តិ គ.អ.ឃុំ គ.អ.ភូមិ អង្គការក្រៅរដ្ឋាភិបាល អ្នកម៉ៅការ និងអ្នកអនុវត្តផ្សេងទៀតនៅតាមផ្នែកឯកជន ។

តាមរយៈការធ្វើពិសោធន៍ជាច្រើន កម្មវិធីសិលា ឥឡូវនេះបានបង្កើតនូវប្រព័ន្ធវិធីសាស្ត្រ និងនីតិវិធី ទាំងមូលដែលតំណាងជារួមនូវគំរូមួយដែលអាចជឿជាក់បានសំរាប់ការយកជាគំរូអនុវត្តតាមនៅក្នុងខេត្តផ្សេងៗទៀត ។ គំរូនេះ បាននាំមកនូវការធ្វើផែនការ និងការអភិវឌ្ឍន៍តាមបែបវិមជ្ឈការ ដោយបង្កើតនូវរចនាសម្ព័ន្ធសំរាប់គ្រប់គ្រងដំណើរការ នីតិវិធី ដែលជួយសំរួលដល់ការសន្ទា រវាងរដ្ឋាភិបាល និងសហគមន៍ ហើយនិងវិធីសាស្ត្រសំរាប់បែងចែកធនធានដល់សហគមន៍មូលដ្ឋាន ។

កម្មវិធីសិលា មានប្រយោជន៍ ក្នុងការបង្កើតនូវគំរូមួយចំនួនសំរាប់កែទំរង់រដ្ឋបាលនៃផ្នែកសាធារណៈ ។ អ្វីដែលគួរឱ្យកត់សំគាល់នៅចំណុចនេះ គឺនីតិវិធី ដែលកម្មវិធីបានទទួលយក ដើម្បីធ្វើឱ្យរដ្ឋាភិបាលកាន់តែឆ្លើយតបបានច្រើនទៅនិងសេចក្តីត្រូវការ និងការទាមទាររបស់សាធារណៈ ដើម្បីជួយសំរួលដល់កិច្ចសហប្រតិបត្តិការ រវាងមន្ទីរជំនាញថ្នាក់ខេត្ត និងសំរាប់ការគ្រប់គ្រង និងការទទួលខុសត្រូវលើការប្រើប្រាស់ថវិកាសាធារណៈ ។ នៅពេលដែលបច្ចេកទេសទាំងនេះត្រូវបានបង្កើតហើយ មិនគ្រាន់តែត្រូវបានអាជ្ញាធរឃុំ និងខេត្ត យកទៅអនុវត្តប៉ុណ្ណោះទេ តែថែមទាំងក្រុមប្រឹក្សាឃុំ និងភ្នាក់ងារសារធារណៈនៅគ្រប់លំដាប់ថ្នាក់នៃរដ្ឋាភិបាលទៀតផង ។

ក្នុងន័យទូលំទូលាយ គំនិតកម្មវិធីសិលា រួមចំណែកដល់គោលដៅរបស់ជាតិក្នុងការលើកស្ទួយ ប្រជាធិបតេយ្យ និងអភិបាលកិច្ចល្អ សំខាន់ជាពិសេសនោះ គឺការសង្កត់ធ្ងន់ទៅលើការផ្លាស់ប្តូរឥរិយាបទ ចំពោះសិទ្ធិ និងការទទួលខុសត្រូវក្នុងចំណោមមន្ត្រីរដ្ឋាភិបាល និងប្រជាជនដែលគេបំរើលើកទឹកចិត្តដល់សហគមន៍ឱ្យបង្ហាញនូវការទាមទារ និងផ្តួចផ្តើមគំនិត ហើយនិងជួយឱ្យប្រជាពលរដ្ឋជាច្រើន មានការគោរពខ្លួនឯង និងការជឿជាក់លើខ្លួនឯង ។

និយាយរួម យើងឃើញថា កម្មវិធី សិលា មានការជាប់ពាក់ព័ន្ធខ្ពស់ជាមួយនិងការកែទំរង់របស់រដ្ឋាភិបាល ដើម្បីប្រជាធិបតេយ្យ និងអភិបាលកិច្ច ហើយនិងមាននយោបាយជាក់ស្តែងក្នុងការអនុវត្តន៍ការកែទំរង់នេះ ដោយមានសក្តានុភាពខ្ពស់ក្នុងការសំរេចបាននូវលទ្ធផលល្អ និងការរីកចំរើនយ៉ាងពិតប្រាកដសំរាប់ប្រទេសជាតិ ។

៥. ភាពយកទៅអនុវត្តតាមបាន

នៅក្នុងផ្នែកខាងដើម យើងអះអាងថា កម្មវិធី សិលា មានការជាប់ពាក់ព័ន្ធយ៉ាងខ្ពស់ ក្នុងបរិបទកែទំរង់ របស់រដ្ឋាភិបាល ដែលទាក់ទងទៅនិងរបបវិមជ្ឈការ និងសហវិមជ្ឈការ ។ មានការទាមទារយ៉ាងខ្លាំង សូមឱ្យរដ្ឋាភិបាលពិនិត្យមើលលើ កម្មវិធី សិលា ( សកម្មភាពប្រតិបត្តិការនៅតាមមូលដ្ឋាន ) ដែលជាយន្តការដ៏សំខាន់ ដើម្បីជួយដល់ការអនុវត្តន៍ក្នុង ការកែទំរង់នេះ ។

បច្ចុប្បន្ន មានការពិភាក្សាអំពីថាតើគេអាចគាំទ្រក្រុមប្រឹក្សាឃុំ បានដោយរបៀបណា ។ គេមើលឃើញថា យ៉ាងហោចណាស់ ក្រុមប្រឹក្សាឃុំ នឹងត្រូវការ ការយកចិត្តទុកដាក់ក្នុងការផ្តល់ឱ្យពួកគេនូវពត៌មាន ការបណ្តុះបណ្តាល និងការគាំទ្រនៅក្នុងដំណើរការដំបូង បន្ទាប់ពីការបោះឆ្នោតហើយ ។ គេក៏មើលឃើញជាមុនផងដែរថា តួនាទី សមត្ថភាព និងសកម្មភាពរបស់ក្រុមប្រឹក្សាឃុំ ហើយនិងការពង្រីកការកសាងសមត្ថភាពដល់ក្រុមប្រឹក្សាឃុំ ក្នុងផ្នែកនេះ នឹងមានការរីកចំរើន និងសំរេចបានជាបណ្តើរៗ ។ និយាយឱ្យងាយ មានភារកិច្ចពីរនៅចំពោះមុខ : ទីមួយគឺការគ្របដណ្តប់ជាបន្ទាន់ទៅលើក្រុមប្រឹក្សាឃុំ ឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ហើយមួយទៀតគឺសំរាប់ការគ្របដណ្តប់សំរាប់រយៈពេលវែង ។

ក្នុងពេលជាមួយគ្នានេះផងដែរ របបសហវិមជ្ឈការឥឡូវនេះកំពុងទទួលបាននូវការយកចិត្តទុកដាក់ជាថ្មី ។ ក្រសួងមហាផ្ទៃកំពុងតែស្ថិតក្នុងដំណើរការពង្រាងនូវក្របខ័ណ្ឌការងារស្របច្បាប់ សំរាប់សហវិមជ្ឈការ ដែលមានប្រសិទ្ធភាពដល់ស្ថាប័នរបស់រដ្ឋ នៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងស្រុក ។

កម្មវិធី សិលា ផ្តល់នូវគំនិតសំរាប់ការធ្វើផែនការ និងការអភិវឌ្ឍន៍មូលដ្ឋាន និងតំបន់ តាមបែបវិមជ្ឈការ និងសហវិមជ្ឈការ ជារួម ។ ដូចនេះ កម្មវិធី សិលា ហាក់ដូចជាមានការជាប់ពាក់ព័ន្ធជាពិសេស និងមានប្រយោជន៍ក្នុងការសំរេចឱ្យបាន ច្រើននូវគោលដៅរយៈពេលវែង ជាជាងសំរេចបានទៅតាមតំរូវការជាក់លាក់ និងជាបន្ទាន់ ក្នុងការ

គាំទ្រដល់ ក្រុមប្រឹក្សាឃុំនៃជាតិទាំងមូល ។ កម្មវិធី សិលា អាចដើរតួក្នុងការបំពេញទៅតាមតំរូវការទាំងនេះ (នៅក្នុងខេត្ត មួយចំនួន ) ប៉ុន្តែយន្តការដ៏ទៃទៀតដែលត្រូវកំណត់ដោយគណៈកម្មាធិការជាតិ សំរាប់ការគាំទ្រដល់ក្រុមប្រឹក្សាឃុំ នោះ នឹងត្រូវបំពេញដល់ការរួមចំណែករបស់កម្មវិធី សិលា ។

កម្មវិធីសិលា គួរតែត្រូវបានគេយកទៅអនុវត្តតាមជាគំរូ ដោយសារកម្មវិធីនេះ មានការជាប់ពាក់ព័ន្ធយ៉ាងខ្ពស់ដល់គោលនយោបាយរបស់រដ្ឋាភិបាល សំរាប់វិមជ្ឈការ និងសហវិជ្ឈការ។ ប៉ុន្តែការអនុវត្តន៍តាមកម្មវិធី សិលា គឺជាការអនុវត្តន៍ តាមនូវគោលគំនិតរបស់កម្មវិធី សិលា ។ ដូចបានបកស្រាយនៅក្នុងផ្នែក គ-១ គំនិតនេះបង្ហាញឱ្យឃើញ នូវគោលការណ៍ មួយចំនួន និងមានវិធីសាស្ត្រមួយចំនួនសំរាប់អនុវត្តគោលគំនិតនេះ ក្នុងការធ្វើផែនការ និងការអភិវឌ្ឍន៍ នៅតាមមូលដ្ឋាន និងនៅតាមតំបន់ ។ ហេតុនេះ ការអនុវត្តន៍តាមកម្មវិធី សិលា មិនមែនជាការបង្រៀនមនុស្សឱ្យ ប្រើប្រាស់ឯកសារ រៀបចំកិច្ចសន្យា និងសរសេររបាយការណ៍តាមដាននោះឡើយ ។ ការអនុវត្តន៍តាម កម្មវិធី សិលា សំខាន់គឺជាការ ផ្លាស់ប្តូរចិត្តគំនិត និងឥរិយាបទ ដោយស្របជាមួយនឹងគោលការណ៍នៃអភិបាលកិច្ចល្អ និង ប្រជាធិបតេយ្យ ។

ដូច្នេះ ភាពអនុវត្តន៍តាមបាននៃកម្មវិធី សិលា មិនមែនជាភារកិច្ចតូចតាចឡើយ ។ ដូចបានបញ្ជាក់នៅក្នុងរបាយការណ៍ នេះរួចមកហើយ វានឹងត្រូវការ នូវការប្រឹងប្រែងរួមគ្នា និងប្រកបដោយគុណភាពខ្ពស់ នៅក្នុងរយៈពេលបន្ថែមនេះដើម្បីធានានូវនិរន្តរភាពគោលគំនិតនៃកម្មវិធី សិលា នៅក្នុងគំនិតរបស់ប្រជាជន និងនៅក្នុងរបៀបនៃការធ្វើផែនការ និងការអភិវឌ្ឍន៍ ។ បទពិសោធន៍នៅក្នុងដំណាក់កាលបច្ចុប្បន្ន បង្កើតបានជាសាក្សីយ៉ាងគ្រប់គ្រាន់លើការងារនេះ។

ឧបសគ្គមួយ ដែលយើងមើលឃើញ ក្នុងការអនុវត្តន៍តាមកម្មវិធី សិលានេះ គឺមានបុគ្គលិកដែលមានជំនាញដែលមិនគ្រាន់តែមិនយល់អំពីគំនិតរបស់កម្មវិធី សិលាប៉ុណ្ណោះទេ តែថែមទាំងបកស្រាយនូវគំនិតអភិវឌ្ឍន៍នេះទៅតាមការគិត របស់គេផ្ទាល់ទៀតផង ។ ឧបសគ្គមួយទៀតគឺ សមត្ថភាពរបស់អង្គភាពគ្រប់គ្រងថ្នាក់ជាតិប្រសិនបើការងារនេះ ត្រូវបញ្ចូលទៅក្នុងស្ថាប័នរដ្ឋាភិបាល ហើយកត្តាទីបី គឺការផ្តល់ថវិកាដោយម្ចាស់ជំនួយ ។

៦. <u>ហានិភ័យ</u>

កម្មវិធី សិលា ប្រឈមមុខនិងឧបសគ្គចំពោះមុខ។ មានការព្រួយបារម្ភកាន់តែច្រើនក្នុងចំណោមបុគ្គលិកគាំទ្ររបស់ ផែ.រ.រ អំពីអនាគត របស់ ផែ.រ.រ នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០០០ ។ ក្នុងទស្សនៈរបស់ពួកគេ បញ្ហា

គឺថា តើពួកគេនឹងមានការងារធ្វើទេបន្ទាប់ពីថ្ងៃនោះទៅ ។ នៅពេលដែលពេលវេលាកាន់តែខិតជិតដល់ការព្រួយបារម្ភ ក៏កាន់តែកើនឡើង ហើយវាពិបាកនឹងភ្ញាក់ផ្អើលពេកស់ ប្រសិនបើបុគ្គលិកជាច្រើន ចាប់ផ្តើមរកការងារថ្មីនៅពេលដែលជិតចប់កុងត្រារបស់ខ្លួនដែលកំពុងមាននោះ ។

បុគ្គលិកគាំទ្រ ឃៃ.វេ.វេ ដែលត្រូវបានជ្រើសរើសនៅក្នុងស្រុក នឹងដើរតួរយ៉ាងសំខាន់ នៅតាមបណ្តាខេត្តដែលមានកម្មវិធី សិលា ហើយពួកគេនឹងត្រូវដើរតួយ៉ាងសំខាន់ក្នុងកម្មវិធីពេកក៏ដោយ សំរាប់ការអនុវត្តន៍តាម កម្មវិធីសិលា និងសំរាប់ការពង្រីកក្តី ។

ការត្រូវការពេលវេលាសំរាប់ ដំណើរការរៀបចំដែលមានពីរដំណាក់កាល និងពេលវេលាសំរាប់ដំណើរការនៃការសំរេចចិត្ត ការរៀបចំរដ្ឋបាល នឹងទាមទារឱ្យមានការព្រមព្រៀងជាចុងក្រោយ និងត្រៀមថវិកា យើងមានការព្រួយបារម្ភយ៉ាងខ្លាំងថា ស្ថានភាពមួយនឹងកើតឡើង ដែលធ្វើឱ្យរាក ដូចបានលើកឡើងខាងដើម ក្លាយទៅជាការពិត ។ យើងបានកត់សំគាល់ថា ក្រុមផ្តល់ការប្រឹក្សារបស់អង្គការស៊ីដា បានផ្តល់ការដាស់តឿននេះម្តងរួចមកហើយ កាលពីខែមិថុនា ឆ្នាំ ១៩៩៩ ។ តាមដែលយើងអាចដឹងបាន មាននៅសល់កិច្ចការដែលពួកគេគិតថាបន្ទាន់មិនទាន់ត្រូវបានដោះស្រាយនៅឡើយ ។ យើងសូមជំរុញដល់ កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ UNDP ព្រមទាំងម្ចាស់ ជំនួយដែលគាំទ្រ ចាត់វិធានការដែលចាំបាច់ ដើម្បីជៀសវាងឧសគ្គនេះ ហើយវិធានការទាំងនេះត្រូវតែបំពេញទៅតាមសេចក្តីត្រូវការ ជាពិសេស របស់បុគ្គលិកដែលអាចនឹងបាត់បង់ ។

គោលគំនិតរបស់កម្មវិធី សិលា ប្រឈមមុខនិងការបាត់បង់ដោយសារហេតុផលមួយចំនួន ។ ហាយនភ័យដ៏ធ្ងន់ធ្ងរមួយគឺ ការយកទៅអនុវត្តតាមដោយប្រញាប់ពេក ។ ក្នុងការយល់ឃើញរបស់យើង ផែនការពង្រីកកម្មវិធីសិលា សំរាប់គ្របដណ្តប់គ្រប់ឃុំ និងគ្រប់ខេត្តទាំងអស់ ដូចដែលបានកំណត់នៅក្នុងផែនការ៥ឆ្នាំរបស់កម្មវិធី សិលា ( ពីឆ្នាំ ២០០១ រហូតដល់ឆ្នាំ ២០០៥ ) នឹងធ្វើឱ្យកម្មវិធី សិលា ធ្លាក់ក្នុងហាយនភ័យបែបនេះ ។

បញ្ហាប្រហែលគ្នានេះដែរ នឹងកើតមានឡើង ប្រសិនបើគំរោងទាំងនេះ ត្រូវបានគេអនុវត្តលឿនពេក ដែលនាំឱ្យមានការអនុវត្តន៍គោលការណ៍ វិធីសាស្រ្ត និងបច្ចេកទេស តាមផ្លូវកាត់ ។ ជាពិសេស ការខំប្រឹងកសាងសមត្ថភាពក្នុងគោលបំណងផ្លាស់ប្តូរឥរិយាបទ និងការយល់ដឹងអំពីតួនាទី ប្រហែលជាត្រូវបាត់បង់យ៉ាងធ្ងន់ ។

គំនិតកម្មវិធី សិលា ក៏អាចទទួលរងនូវការខូចខាត និងការភាន់ច្រឡំ ប្រសិនបើម្ចាស់ជំនួយ ក្រៅពីអ្នកគាំទ្រកម្មវិធី សិលា អនុវត្តនូវគំរោងដូចគ្នាក្នុងខេត្តដែលមានកម្មវិធី សិលាដែរ តែប្រតិបត្តិតាមគោលការណ៍ផ្សេង ហើយអនុវត្តនូវវិធីសាស្រ្តផ្សេងនោះ ។ បុគ្គលិកថ្នាក់ខេត្ត និងថ្នាក់ស្រុកមិនអាច អនុវត្ត និងប្រតិបត្តិតាម គោលការណ៍របស់កម្មវិធី សិលា នៅពេលព្រឹក រួចហើយអនុវត្តតាមគោលការណ៍ផ្សេងទៀតនៅពេលរសៀលបានឡើយ ។ បញ្ហានេះ

អាចកើតមានឡើងនៅក្នុងខេត្តទាំងឡាយណាដែលមានការទទួលយកប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់កម្មវិធី សិលា ជំរុញឱ្យម្ចាស់ជំនួយ "ធ្វើតាមប្រពន្ធ័" កម្មវិធីនោះ នៅពេលដែលមានអនុវត្តគំរោងដែលមានគោលគំនិតផ្សេងៗពីរបស់កម្មវិធី សិលា។ វាជាសំណួរបើកចំហរមួយ ថាតើ គេអាចយកគំរូ កម្មវិធី សិលាទៅអនុវត្ត នៅ ក្នុងខេត្តនានាដែលមានគំរោងកំពុងដំណើរការ ហើយប្រតិបត្តិនូវគោលការណ៍ផ្សេងៗគ្នាបានយ៉ាងដូចម្តេច ។ ខេត្តទាំងឡាយដែលត្រូវបានគេពិចារណា សំរាប់ការអនុវត្តតាមនេះ នឹងត្រូវដោះស្រាយមួយករណីម្តងៗក្នុងបញ្ហានេះ ដើម្បីពិនិត្យមើលថាតើភាពខុសគ្នាណាខ្លះ ដែលអាចកែតំរូវបាន ។

កម្មវិធី សិលា អាចស្ថិតនៅក្នុងសម្ពាធមួយ ក្នុងការពង្រីកសកម្មភាពរបស់ខ្លួន ដែលជាមធ្យោបាយជួយរដ្ឋាភិបាល ក្នុងការកែទំរង់ថ្នាក់ឃុំ ។ នៅក្នុងផ្នែក ភាពជាប់ទាក់ទង និងភាពយកទៅអនុវត្តតាមបាន យើងបានអះអាងថា គំនិតរបស់កម្មវិធី សិលា មានតួនាទីយ៉ាងសំខាន់ ក្នុងការគាំទ្រដល់គោលដៅរបស់រដ្ឋាភិបាល ដើម្បីរបបវិមជ្ឈការ និង សហវិមជ្ឈការ តែថា ការរួមចំណែករបស់កម្មវិធី សិលា គួរតែបំរើ គោលបំណងរយៈពេលវែងជាជាងតំរូវការបន្ទាន់ ។ កម្មវិធីសិលា មិនមែនជាយន្តការតែមួយគត់សំរាប់គាំទ្រដល់ក្រុមប្រឹក្សាឃុំនោះឡើយ ។

ផ្អែកតាមការអះអាងនេះ យើងសូមឱ្យមានការពង្រីកកម្មវិធី សិលាទៅក្នុងខេត្តថ្មីៗ ឱ្យបានសមស្រប និងបន្តិចម្តងៗ ដោយមិនកំណត់តំបន់គោលដៅជាក់លាក់ សំរាប់ការគ្របដណ្តប់ឡើយ ។ ការពង្រីក គួរតែផ្តោតទៅលើ ខេត្តថ្មីចំនួនពីរ ឬបី ដោយបន្ថែមទៅលើការរីកចំរើននៅក្នុងខេត្តដែលមានកម្មវិធីក្នុងពេលបច្ចុប្បន្ន ។ ការពង្រីកបន្ថែមទៀត គួរតែអាស្រ័យទៅតាមការពិនិត្យឡើងវិញនូវនិរន្តរភាព និងគំនិត នៅក្នុងខេត្តដែលមានស្រាប់ ហើយការ វិភាគ ទៅលើបទពិសោធន៍នៃការអនុវត្តន៍តាម នៅក្នុងខេត្តថ្មីៗ ឧទាហរណ៍ បន្ទាប់ពីរយៈពេលពីរឆ្នាំ ។

*ឃ. <u>មេរៀនដែលបានរៀន</u>*

នៅពេលមានបរិបទទាំងឡាយខុសៗគ្នា បទពិសោធន៍កម្មវិធី សិលា ផ្តល់នូវឱកាសរៀនសូត្រ មិនមែនតែសំរាប់ ប្រទេសកម្ពុជាប៉ុណ្ណោះទេ តែក៏សំរាប់ប្រទេសដទៃផងដែរទាក់ទងគោលនយោបាយសំរាប់របបវិមជ្ឈការ និង សហវិមជ្ឈការ។ រីឯ កម្មវិធីបែបនេះ ត្រូវបានគេព្យាយាមធ្វើនៅក្នុងប្រទេសជាច្រើន ករណីនៃការទទួលជោគជ័យមានប្រហាក់ប្រហែល នឹងកម្មវិធី សិលាដែរ ប៉ុន្តែមិនដូចគ្នាទាំងស្រុងទេ ។ ប្រហែលមេរៀនមួយដែលសំខាន់នោះគឺថា របបវិមជ្ឈការ និងសហវិមជ្ឈការ នៃការធ្វើផែនការ និងការអភិវឌ្ឍន៍ អាចទទួលបានជោគជ័យ ទោះជានៅប្រទេសមួយចំនួន ដូចជាប្រទេសកម្ពុជាក្តី ដោយមានរចនាសម្ព័ន្ធសង្គម តាមលំដាប់ថ្នាក់ និងទំនាមទំលាប់ការិយាល័យនិយម បែបមជ្ឈការ ដែលមានការទាក់ ទងជាបឋមទៅនឹងច្បាប់ សណ្តាប់ធ្នាប់ និងសន្តិសុខ ។

<u>មានមេរៀនមួយចំនួនទៀត ដែលមានសង្ខេបដូចខាងក្រោម</u> :

- ការរៀនសូត្រ ដោយការធ្វើបណ្ដើរ ជាមួយនឹងអ្នកអនុវត្តជាច្រើន តាំងពីថ្នាក់ខេត្ត រហូតដល់ថ្នាក់សហគមន៍ បានបង្ហាញនូវ វិធីសាស្ត្រមួយដែលមានប្រសិទ្ធភាពខ្ពស់ ចំពោះការបង្កើតគំនិត របបវិមជ្ឈការ និងសហវិមជ្ឈការ ហើយនិងការកសាងសមត្ថភាព ។
- ការបង្កើត និងការអនុវត្តន៍នូវគំនិតវិមជ្ឈការ និងសហវិមជ្ឈការទាមទារនូវការប្រឹងប្រែង ដែលឆ្លើយតប ទៅប្រព័ន្ធ ទាំងមូល រាប់បញ្ចូលទាំងអ្នកដើរតួជាច្រើន នៅកំរិតផ្សេងៗគ្នា ( ថ្នាក់ខេត្ត ថ្នាក់ស្រុក ) សភារដ្ឋាភិបាលមូលដ្ឋាន និងស្ថាប័នសង្គមស៊ីវិល ។
- ដំណើរការនៃការបង្កើត គំនិតនេះ គួរតែរៀបចំធ្វើឡើងទៅតាម ការធ្វើពិសោធន៍ ការរៀនសូត្រ និង ការកែតំរូវ ។
- ទោះជាគេមើលឃើញថាវាជាសកម្មភពសាកល្បង ឬ ជាការធ្វើពិសោធន៍ក្នុងរបបវិមជ្ឈការ និងសហវិមជ្ឈការក្ដី ការប្រឹងប្រែង ត្រូវតែមានទំហំគ្រប់គ្រាន់ ដើម្បីគ្របដណ្ដប់ប្រព័ន្ធទាំងមូលនៅក្នុងតំបន់ ( ឧ: នៅក្នុងខេត្ត ) ។ ទំហំក៏សំខាន់ដែរ ដើម្បីបង្ហាញពីភាពទាក់ទង ។
- កត្តាសំខាន់ ចំពោះភាពជោគជ័យ គឺតួនាទីគាំទ្រ ដ៏រឹងមាំ និងប្រកបដោយគុណភាព ដែលបង្កើតឡើងនូវគំនិតច្នៃប្រឌិត ក្នុងការបង្កើតវិធីសាស្ត្រផ្សេងៗ និងធ្វើឱ្យមានឥរិយាបទ ការទទួលយក និងការយល់ដឹង យ៉ាងច្រើន អំពីរបបវិមជ្ឈការ / សហវិមជ្ឈការ ហើយផ្ដល់នូវការកសាងសមត្ថភាព ដ៏ទូលំទូលាយ និងយូរអង្វែង ។
- កត្តាផ្សេងៗ ក្រៅពីការប្រឹងប្រែង ដើរតួយ៉ាងសំខាន់ ក្នុងការកំណត់អំពីការរីកចំរើន និងការជោគជ័យ ។ កត្តាជាក់លាក់មួយចំនួន នៃភាពសំខាន់ពិសេស ចំពោះកម្មវិធី សិលា គឺជាភាពអវត្តមាននៃធនធាន និងការដឹកនាំ នៅថ្នាក់ខេត្ត នៅពេលដែលបុព្វការីជនបានចូលមកក្នុងវេទិការ ( អ្នកបង្កើតកម្មវិធី ចូលមកអនុវត្តកម្មវិធី ) និងម្ចាស់ជំនួយដែលគាំទ្រ និងឥរិយាបទរបស់រដ្ឋាភិបាល ហើយថ្មីៗនេះ គឺការ ប្ដេជ្ញាចិត្តរបស់រដ្ឋាភិបាលថ្នាក់ជាតិ ដើម្បីបន្តដំណើរការធ្វើឱ្យមានប្រជាធិបតេយ្យ តាមរយៈវិមជ្ឈការ ។
- ជាការសំខាន់ណាស់ក្នុងការពិចារណាទៅលើគោលបំណងយូរអង្វែង នៃការធ្វើពិសោធន៍នៅពេលដែលគេរៀបចំគំរោងឡើង ។ គេអាចសន្សំទាំងពេលវេលា និងធនធានបានយ៉ាងច្រើន ប្រសិនបើអ្វីដែលនឹង

ក្លាយទៅជាកម្មវិធី សិលា នាពេលខាងមុខនោះ ត្រូវបានគេរៀបចំដោយចាប់ផ្តើមឡើង ស្របនិងទិសដៅនៃការចំលងកម្មវិធីបន្តរបស់ជាតិត្រូវបានមាននៅក្នុងកំនិត ។

- តាមដែលអាចធ្វើទៅបាន គេគួរចាត់វិធានការដ៏សមស្របទាំងឡាយ ដើម្បីជាសវាងនូវការយលថា ការប្រឹងប្រែង និងលទ្ធផលទាំងនោះ មានទំនាក់ទំនងយ៉ាងខ្លាំង ទៅនិង ម្ចាស់ជំនួយណាមួយ ។ ដោយសារតែការយល់បែបនេះ ធ្វើឱ្យម្ចាស់ជំនួយផ្សេងៗទៀត មិនសូវមានការចាប់អារម្មណ៍ ។
- តាមការយល់ឃើញរបស់ពួកយើង ទាំងអស់នេះហាក់ដូចជាការរៀនយ៉ាងសំខាន់បំផុត ពីបទពិសោធន៍ នៃកម្មវិធី សិលា។ ដោយហេតុថា កម្មវិធី សិលា ឥឡូវឆ្លងចូលដល់ដំណាក់ការថ្មីមួយទៀត ជាមួយនិងការផ្លាស់ប្តូរយ៉ាងសំខាន់លើបរិបទ ដែលទាក់ទងដោយផ្ទាល់ទៅលើកម្មវិធី សិលា ហើយ និងតួនាទី ដែលកម្មវិធី សិលា ជាអ្នកអនុវត្ត ។ មេរៀនសំខាន់ៗដទៃទៀត ទំនងជានឹងត្រូវកើតមានឡើងផងដែរ ។ មេរៀនទាំងនេះ គួរត្រូវបានចងក្រង វិភាគ និងយកទៅ រីកញែក ។

## ខ. អនុសាសន៍

ជំពូកនេះធ្វើការសង្ខេបទៅលើអនុសាសន៍ទាំងឡាយ ដែលមាននៅក្នុងជំពូកមុនៗ និងមានរាប់បញ្ចូល អនុសាសន៍យ៉ាងល្អិតល្អន់ជាច្រើន ទៅលើប្រការជាក់លាក់មួយចំនួន ។

### ១. ការបន្ត

- ដើម្បីធានានូវការបន្តនៃកម្មវិធី ម្ចាស់ជំនួយគួរបន្តអណត្តិនៃដំណាក់ការបច្ចុប្បន្ន (ឧទាហរណ៍ សំរាប់រយៈ ពេល ៦ ខែ) ដើម្បីអាចអោយមានពេលវេលាគ្រប់គ្រាន់ក្នុងការបង្កើតសមាសភាពម្ចាស់ជំនួយ និង សមាសភាពជាតិ អោយបានសមស្រប និងដើម្បីរក្សាធនធានមនុស្សដ៏មានតំលៃដែលកំពុងមានស្រាប់ ។

### ២. ការយកចិត្តទុកដាក់របស់កម្មវិធី

- ការយកចិត្តទុកដាក់ជាបឋមរបស់កម្មវិធីដែលមាន ហើយដែលគួរតែបន្តអោយមានតទៅទៀតនោះ គឺការ កសាងសមត្ថភាពដើម្បីអនុវត្តប្រព័ន្ធមួយនៃការធ្វើផែនការ និងការអភិវឌ្ឍន៍តាមបែបវិមជ្ឈការ និងតាម បែប សហវិមជ្ឈការ ។

- កម្មវិធីនេះ មិនគួរក្លាយទៅជាយានមួយជាចំបង សំរាប់ការកសាងសមត្ថភាពក្រុមប្រឹក្សាឃុំទេ ។ ការងារទាំងនេះ គួរធ្វើដោយកម្មវិធីផ្សេងៗដែលរៀបចំឡើងជាពិសេសសំរាប់គោលបំណងនេះ ។ ការរួមចំណែករបស់កម្មវិធី សិលា គួរបំរើអោយទស្សនៈយូរអង្វែង ជាជាងឆ្លើយតបនិងតំរូវការបន្ទាន់ ។

## ៣. យុទ្ធសាស្ត្រសំរាប់ការអនុវត្តន៍តាមកម្មវិធី សិលា

- កម្មវិធី សិលា គួរត្រូវបានគេចំលងបន្តជាគំរូ ព្រោះថាវាមានទំនាក់ទំនងយ៉ាងខ្ពស់ទៅបរិបទនៃគោលនយោបាយវិមជ្ឈការ និងសហវិមជ្ឈការទាំងឡាយរបស់រាជរដ្ឋាភិបាល ។
- ទោះជាយ៉ាងណាក៏ដោយ ការចំលងបន្តជាគំរូទៅកាន់ខេត្តថ្មីៗទៀត គួរធ្វើឡើងដោយសមស្រប និងដោយសន្សឹមៗ ដោយមិនកំណត់តំបន់គោលដៅជាក់លាក់ សំរាប់វិសាលភាពគ្របដណ្តប់ ។ សេចក្តីសំរេចចិត្តក្នុងការពង្រីកបន្ថែម គួរធ្វើឡើងដោយគិតគូរពិចារណាទៅលើលទ្ធភាពដែលអាចរកបាននូវមនុស្សដែលមានសមត្ថភាពដើម្បីបំរើការងារជាបុគ្គលិកគាំទ្រ និងសមត្ថភាពរបស់អង្គភាពដឹកនាំកម្មវិធីជាតិ ។
- មុននឹងឈានចូលទៅក្នុងខេត្តថ្មីៗទៀត កម្មវិធី សិលា គួរតែវិភាគទៅលើសមត្ថភាព ( ដែលជាផ្នែកនៃសេចក្តីត្រូវការមួយ ) ដើម្បីអាចអោយមានឱកាសដ៏ល្អសំរាប់ជួយគ្នា ប្តូរពទពិសោធន៍រវាងខេត្តថ្មី និងខេត្តដែលមានកម្មវិធី សិលា ស្រាប់ និងដើម្បីធ្វើអោយកម្មវិធីមាន ភាពស៊ីសង្វាក់គ្នាជាមួយ និងកម្មវិធីដទៃទៀតដែលកំពុងអនុវត្តនៅក្នុងខេត្តថ្មី ។

## ៤. យុទ្ធសាស្ត្រសំរាប់ការកសាងសមត្ថភាព

- វិធីសាស្ត្រដើម្បីកសាងសមត្ថភាព គួរធ្វើឡើងដោយផ្អែកទៅលើគោលការណ៍ "រៀនសូត្រតាមរយៈ ការងារ" ហើយឈរលើគោលបំណងនេះ ថវិកាគួរតែត្រូវផ្តល់អោយជារួមសំរាប់ទាំងការកសាង សមត្ថភាព និងសកម្មភាពការងារអភិវឌ្ឍន៍ ។
- នៅថ្នាក់ខេត្ត ការកសាងសមត្ថភាពគួរល្អិតល្អន់ ទូលំទូលាយ និងយូរអង្វែង ។ ល្អិតល្អន់ មានន័យថា ស្មើរស្មើនិងកីរិតគាំទ្របច្ចុប្បន្នក្នុងខេត្តនិមួយៗ ។ ទូលំទូលាយ មានន័យថា រាប់បញ្ចូលទាំងមន្ទីរជំនាញពាក់ព័ន្ធនិងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ( ដែលនឹងត្រូវសំរេចដោយខេត្ត និមួយៗ ) ។

- នៅថ្នាក់ជាតិ ការកសាងសមត្ថភាពគួរតែមាន ការទាក់ទិន ភាពយូរអង្វែង និងដោយផ្តោតការយកចិត្តទុកដាក់ទៅលើអ្នករៀបចំគោលនយោបាយជាន់ខ្ពស់ អង្គនិតិប្រតិបត្តិ និងជនបង្គោល របស់ក្រសួង ហើយពួកគេ គួរចូលរួមក្នុងការរៀបចំបង្កើតសកម្មភាពការងារនេះ ។
- ក្នុងការចំលងបន្តនូវគំរូនៃកម្មវិធី សិលា ទៅក្នុងខេត្ត និងស្រុកថ្មីៗទៀត ការកសាងសមត្ថភាពគួរផ្តល់ដល់អ្នកអនុវត្តកម្មវិធីគ្រប់ជាន់ថ្នាក់ទាំងអស់ ។
- តួនាទីគាំទ្រគួរតែខ្លាំងនិងត្រូវមានបុគ្គលិកជាមនុស្សមានសមត្ថភាព ដើម្បីធ្វើអោយប្រាកដថា គោលការណ៍នៃគោលគំនិតសិលាត្រូវបានរក្សាទុក ចំពោះមុខនៃមហិច្ឆតានៃការពង្រីកតំបន់គោលដៅ និងពេលវេលាគ្រោងទុក ។
- ការកសាងសមត្ថភាពគួរតែមានការបត់បែនបាន ដើម្បីអាចអោយមានការកែសំរួលនៅថ្នាក់មូលដ្ឋាន ចំពោះបរិយាកាសនៃការអនុវត្តតាមកម្មវិធិសិលាក្នុងទ្រង់ទ្រាយធំដែលយើងនឹងត្រូវជួបប្រទះ ។ ការបត់បែនគួរផ្តោតទៅលើការជំរុញលើភាពទាក់ទង និងភាពជាម្ចាស់ នៅមូលដ្ឋាន។
- មុននឹងចំលងបន្តគំរូទៅកាន់ខេត្តថ្មីៗទៀត ការណែនាំ និងការកសាងសមត្ថភាពគួរធ្វើឡើងដោយសង្កត់ធ្ងន់ទៅលើការងារតួនាទីបុរស-ស្ត្រី និងបញ្ហាដែលជួបប្រទះ ។
- មុននឹងធ្វើការបែងចែកធនធានកសាងសមត្ថភាព ការវាយតំលៃលើសមត្ថភាពយ៉ាងពិស្តារមួយ គួរធ្វើឡើងនៅក្នុងខេត្តថ្មីៗ ដោយរាប់បញ្ចូលទាំងសក្តានុពលនៃគំរោង និងកម្មវិធិដទៃទៀត ដើម្បីរួមចំណែកក្នុងការសំរេចទិសដៅនៃកម្មវិធី សិលា ។
- យុទ្ធសាស្ត្រចំលងបន្តនេះ គួរពិចារណាទៅលើមូលដ្ឋានធនធានមនុស្សដែលមានស្រាប់នៅក្នុងខេត្ត សិលាទាំងឡាយ ហើយនិងប្រើប្រាស់អ្នកទាំងនោះនៅក្នុងការកសាងសមត្ថភាពនា ពេលអនាគត ។ ទិន្នន័យជាមូលដ្ឋានអំពីសមត្ថភាព គួរត្រូវបានកត់ត្រាទុកផងដែរ ដើម្បីជួយសំរួល ដល់ការវាយតំលៃនាពេលអនាគត ។

## ៥. រចនាសម្ព័ន្ធគ្រប់គ្រង

- ក្នុងទិដ្ឋភាពនៃការផ្តួចផ្តើមរបស់រាជរដ្ឋាភិបាល ក្នុងការកែទំរង់រដ្ឋបាលតាមបែបវិមជ្ឈការ និង សហវិមជ្ឈការ វិធានការណ៍ទាំងឡាយគួរធ្វើឡើងដើម្បីរៀបចំតួនាទីរបស់កម្មវិធី ឈែរេរ នៅក្នុងរចនាសម្ព័ន្ធរបស់រាជ-រដ្ឋាភិបាល ។

- ស្ថាប័នបង្កើតគោលនយោបាយ គួរត្រូវបានពង្រឹងឡើងអោយបានរឹងមាំ ។ គួរកំណត់នូវអេហេតុ និងការទទួលខុសត្រូវក្នុងការធ្វើសេចក្ដីសំរេចចិត្តអោយបានច្បាស់លាស់និងត្រូវបានគាំទ្រយ៉ាងខ្លាំង ដោយលេខាធិការដ្ឋានប្រតិបត្តិ ។
- នៅថ្នាក់ជាតិ ការទទួលខុសត្រូវក្នុងការគ្រប់គ្រងកម្មវិធី សិលា គួរត្រូវបានរៀបចំនៅក្នុងស្ថាប័នរាជរដ្ឋាភិបាល ដូចជាលេខាធិការដ្ឋានប្រតិបត្តិមួយដែរ ។
- ផ្នែកគ្រប់គ្រងនេះ គួរមានទីតាំងរដ្ឋបាលនៅក្រោមទីភ្នាក់ងារដឹកនាំអព្យាក្រិត្យមួយ ដែលមាន សមត្ថភាពផ្ដល់នូវភាពដឹកនាំខ្លាំង និងសិទ្ធិអនុញ្ញាតិត្រូវបានគេគោរព ហើយដែលមានលទ្ធភាពអាចសំរបសំរួលជាមួយនិងបណ្ដាក្រសួងជំនាញដែលពាក់ព័ន្ធ ។
- លក្ខខ័ណ្ឌចាំបាច់គួររៀបចំឡើងដើម្បីរក្សាក្រុមគាំទ្រដ៏ខ្លាំងមួយ ក្នុងការបំរើការងារទាំងថ្នាក់ជាតិ និងថ្នាក់ខេត្ត ។
- នៅថ្នាក់ជាតិ ក្រុមគាំទ្រគួរធ្វើការជាមួយនិងផ្នែកគ្រប់គ្រង ប៉ុន្តែនៅថ្នាក់ខេត្ត សមាជិកទាំងឡាយ គួរបែងចែកទៅតាមចំណុចយុទ្ធសាស្ត្រនានា ជាកន្លែងដែលពួកទាំងនោះអាចធ្វើអោយមានឥទ្ធិពលខ្លាំង ។
- បុគ្គលិកគាំទ្រ គួរធ្វើការនៅកន្លែងជាមួយគ្នាទៅតាមរចនាសម្ពន្ធ័សិលា ដើម្បីអាចអោយពួកគេប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកយ៉ាងមានប្រសិទ្ធភាព ហើយក្រុមនេះ គួរទទួលបានការបែងចែកថវិកា គ្រប់គ្រាន់ដើម្បីធ្វើការទាក់ទាញការចាប់អារម្មណ៍ពីអ្នកដែលមានសមត្ថភាព និងដើម្បីអាចអោយ ក្រុមនេះបានចុះទៅធ្វើការនៅតាមមូលដ្ឋានបានញឹកញាប់ និងមានប្រសិទ្ធភាពក្នុងការបំពេញការងារធ្វើ ការរបស់គេ ។
- ចំពោះអ្នកដែលមានការពាក់ព័ន្ធក្នុងការបង្កើតកម្មវិធីសំរាប់ពេលបន្ទាប់នេះ គួរកុំអោយមានគំនិតជិត ជាប់ជាមួយនិងបញ្ហាដែលថា តើនរណានិងទទួលខុសត្រូវកម្មវិធី សិលា នេះខ្លាំងពេក ។ កម្មវិធី និងគោលគំនិតរបស់វា យើងអាចធ្វើការផ្ទេរបាន ។ បញ្ហាដែលសំខាន់នោះគឺត្រូវធ្វើអោយប្រាកដថា គោលគំនិតនោះត្រូវបានរក្សា និងយល់យ៉ាងច្បាស់ ដោយអ្នកដែលទទួលខុសត្រូវលើកម្មវិធី ។

## ៦. ការផ្ដល់មូលនិធិ

- រាល់មូលនិធិដែលផ្ដល់ដោយម្ចាស់ជំនួយនាអនាគត សំរាប់កម្មវិធី សិលា គួរធ្វើឡើងតាមរយៈនៃ រចនាសម្ព័ន្ធរបស់រាជរដ្ឋាភិបាល (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្ដល់ទៅអោយខេត្ត) ហើយថវិកាទាំងនេះត្រូវរាប់បញ្ចូលទៅក្នុងថវិកាជាតិ ។

- ដើម្បីរក្សាគោលការណ៍ដែលថា រៀនបណ្តើរអនុវត្តបណ្តើរ មូលនិធិរបស់ម្ចាស់ជំនួយគួរផ្តល់ជូនសំរាប់ការកសាងសមត្ថភាព និងសកម្មភាពគំរោងអភិវឌ្ឍន៍នានា ក្នុងខ្ទង់ថវិកាតែមួយ ។

## ៧ - ប្រព័ន្ធនាំចេញរបស់កម្មវិធី

### ក - ប្រព័ន្ធហិរញ្ញវត្ថុ

- កម្មវិធី សិលា គួរពិចារណាសារជាថ្មី អំពីនីតិវិធីទូទាត់ថវិកាជាមួយ និងអ្នកម៉ៅការទាំងឡាយ ដោយធ្វើការផ្ទេរភារៈកិច្ចទទួលខុសត្រូវទាំងនេះអោយទៅគណៈកម្មាធិការអភិវឌ្ឍន៍ឃុំវិញ នៅពេលដែលអាចធ្វើទៅបាន ។ ហើយកម្មវិធី សិលា គួរតែអនុវត្តនូវការកសាងសមត្ថភាពដែលចាំបាច់ដល់គណៈកម្មការទាំងនោះ ។
- កម្មវិធី សិលា គួរពិភាក្សាជាមួយគណៈកម្មាធិការជាតិដើម្បីគាំទ្រ ក្រុមប្រឹក្សាឃុំនៅពេលដែលគេ បង្កើតឡើង ដើម្បីគិតគូអំពីតួនាទីនៃមូលនិធិអភិវឌ្ឍន៍មូលដ្ឋាន និងថវិកាចំណូលរបស់ឃុំ (ដែលយើងមើលឃើញថាអាចនិងមាននៅក្នុងច្បាប់រដ្ឋបាលឃុំ) ។

## ខ - ដំណើរការកសាងផែនការមូលដ្ឋាន

- ដំណើរការកសាងផែនការមូលដ្ឋាន គួរធ្វើអោយមានភាពងាយស្រួលជាងមុនបន្តទៀត ។ ជំហានទាំងឡាយគួរធ្វើឡើងដើម្បីកាត់បន្ថយនូវដំណាក់កាលមួយចំនួន ដែលធ្វើអោយមានភាពខុស ប្លែកគ្នាតែបន្តិចបន្តួចចំពោះលទ្ធផល និងដើម្បីកាត់បន្ថយការខិតខំប្រឹងប្រែងក្នុងការបញ្ចូលទិន្នន័យ មូលដ្ឋាន និងដើម្បីកាត់បន្ថយនូវតំរូវការជំនួយបន្ថែម ពីសំណាក់អ្នកសំរបសំរួល ។
- វិធីសាស្ត្របច្ចុប្បន្នទាំងឡាយ និងនីតិវិធីនានា ដែលមាននៅក្នុងដំណើរការកសាងផែនការដើម្បីអោយមានការចូលរួមពីអ្នកភូមិ និងការកសាងសមត្ថភាព គួររក្សាទុកអោយមាននៅដដែល ។
- ការខិតខំប្រឹងប្រែងសហការទាំងឡាយ គួរធ្វើឡើងដើម្បីលើកទឹកចិត្តអោយមានការចូលរួមយ៉ាងច្រើនឡើងពីសំណាក់មន្ទីរជំនាញទាំងឡាយ និងអង្គការក្រៅរដ្ឋាភិបាលនានា នៅក្នុងសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក ។
- វីធីទាំងឡាយអាចត្រូវបានគេមើលឃើញផងដែរ ក្នុងការផ្តល់ថវិកាមូលនិធិអភិវឌ្ឍន៍មូលដ្ឋានសំរាប់ប្រតិបត្តិការងាររយៈពេលពីរឆ្នាំម្តង១ជាប់គ្នា នេះដើម្បីអោយការរៀបចំកិច្ចសន្យា និង ការសាងសង់អាចអនុវត្តបានក្នុងរយៈពេលពេញមួយឆ្នាំនៃឆ្នាំនិមួយ១ ។

- បញ្ជីសកម្មភាពនានាដែលសមស្របក្នុងការប្រើប្រាស់ថវិកាមូលនិធិអភិវឌ្ឍន៍មូលដ្ឋាន គួរតែមានបន្ថែមទៅលើសកម្មភាពនៃគំរោងហេដ្ឋារចនាសម្ព័ន្ធតូចៗ ដោយបញ្ចូលអោយមាននូវការងារ និងសេវាសាធារណៈដទៃទៀតផង ប៉ុន្តែមិនមែនសកម្មភាពសេដ្ឋកិច្ចឡើយ ។ អ្នកសំរបសំរួលការងារគួរយល់ដឹងអំពី សកម្មភាពទាំងឡាយដែលសមស្រប និងគួរលើកទឹកចិត្តសហគមន៍អោយពិចារណាអំពីសកម្មភាពការងារទាំងនោះ ។
- កម្មវិធី សិលា គួរពិភាក្សាជាមួយនិងគណៈកម្មាធិការជាតិដើម្បីគាំទ្រក្រុមប្រឹក្សាឃុំ នៅពេលដែលគេបង្កើតឡើងដើម្បីចាត់វិធានការក្នុងការការពារ និងប្រើប្រាស់នូវធនធានមនុស្ស ដែលបានបណ្តុះបណ្តាលឡើងដោយកម្មវិធី សិលា ក្នុងចំណោមគណៈកម្មាធិការ អភិវឌ្ឍន៍ភូមិ និងឃុំ ។

## គ ៈ ដំណើរការកសាងផែនការខេត្ត

- កម្មវិធី សិលា គួរបន្តការខិតខំប្រឹងប្រែងជាមួយនិងក្រសួងផែនការដើម្បីគិតគូរ និងធ្វើអោយប្រសើរ ឡើងនូវការប្រើប្រាស់ផែនការអភិវឌ្ឍន៍ និងផែនការវិនិយោគខេត្ត អោយទៅជាផ្នែកមួយសំខាន់នៃផែនការជាតិ ។
- ជំនួយបន្ថែមទៀត គួរត្រូវស្វែងរកដើម្បីបង្កើតវិធីសាស្ត្រដ៏ល្អថែមទៀតសំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋាន និងធ្វើអោយផែនការអភិវឌ្ឍន៍ខេត្តក្លាយទៅជា ឧបករណ៍ដែលមានសក្តានុពលខ្លាំងថែមទៀត សំរាប់ដឹកនាំទិសដៅនាពេលអនាគត ។
- សមាសភាពទាំងឡាយនៃដំណើរការកសាងផែនការខេត្ត គួររក្សាទុកអោយនៅដដែល និងធ្វើការពង្រឹងឡើងថែមទៀត ។ សមាសភាពទាំងនេះមានរាប់បញ្ចូលទាំងជំនួយឥតលក្ខខ័ណ្ឌ ដែលផ្តល់ដោយកម្មវិធី សិលា សំរាប់សកម្មភាពការងារនៃបណ្តាមន្ទីរជំនាញ នីតិវិធីដើម្បីធ្វើអោយប្រសើរឡើងនូវការសហការ និងការសំរបសំរួលរវាងមន្ទីរជំនាញទាំងឡាយនៅក្នុងខេត្ត និងវិធីសាស្ត្រធ្វើអោយសកម្មភាពការងារវិស័យ ទាំងនោះមានការទទួលសុសត្រូវ និងឆ្លើយតបទៅនិងតំរូវការ និងសេចក្តីត្រូវការរបស់មូលដ្ឋានកាន់តែច្រើនឡើងថែមទៀត ។

## ឃ - តួនាទីបុរស-ស្ត្រី

- កម្មវិធីធំៗដែលមានបញ្ចូលការងារតួនាទីបុរស-ស្ត្រី និងសេចក្តីណែនាំ គួររៀបចំឡើងសំរាប់ប្រើប្រាស់នៅក្នុងខេត្ត សិលា ទាំងអស់ធ្វើជាក្របខ័ណ្ឌយុទ្ធសាស្ត្រនៃតួនាទីបុរស-ស្ត្រីយូរអង្វែង ។

- មុននឹងមានសកម្មភាពនៃការធ្វើផែនការនៅក្នុងខេត្តថ្មីៗ ខេត្តទាំងនោះគួរតំរូវអោយមានការយល់ដឹងអំពីតួនាទីបុរស-ស្ត្រី ដែលអាចរាប់បញ្ចូលទាំងការបង្ហាញនូវបទពិសោធន៍ និងការអនុវត្តន៍ដែលល្អប្រសើរទាំងឡាយ ដែលមានស្រាប់នៅក្នុងខេត្ត សិលា ទាំងអស់ ។
- ការកសាងសមត្ថភាពដែលទាក់ទងទៅនិងការយល់ដឹងអំពីតួនាទីបុរស-ស្ត្រី និងកម្មវិធីដែលមានបញ្ចូលតួនាទីបុរស-ស្ត្រី គួរអនុវត្តឡើងនៅថ្នាក់នយោបាយ និងថ្នាក់ប្រតិបត្តិ នៃកម្មវិធី សិលា។
- ការជ្រើសរើសជនបង្គោលសំរាប់ការងារតួនាទីបុរស-ស្ត្រី គួរពិចារណាមិនត្រឹមតែទៅលើសមត្ថភាព យល់ដឹងអំពីបញ្ហាតែប៉ុណ្ណោះទេ ក៏ប៉ុន្តែយើងត្រូវពិចារណាទៅលើលទ្ធភាពជាយុទ្ធសាស្ត្រ ដើម្បីធ្វើ អោយមានឥទ្ធិពលទៅលើដំណើរការសមាហរណកម្ម តួនាទីបុរស-ស្ត្រី ផងដែរនៅក្នុងស្ថាប័ន ទាំងនោះ ។
- បរិយាកាសគាំសំរាប់ជនបង្គោលតួនាទីបុរស-ស្ត្រី គួរពង្រឹងតាមរយៈបណ្តាញការងារទាំងនៅក្នុង ខេត្តនិងនៅក្នុងចំណោមខេត្ត សិលា ទាំងអស់ក្នុងគោលបំណងលើកកំពស់ទំនាក់ទំនង និងការផ្លាស់ ប្តូរពត៌មាន ។
- ឥទ្ធិពល និងប្រសិទ្ធភាពនៃវិធីសាស្ត្របង្រៀនតួនាទីបុរស-ស្ត្រី មាតិការបង្រៀន និងសកម្មភាពការងារពាក់ព័ន្ធទៅនិងតួនាទីបុរស-ស្ត្រី ដទៃទៀត ដែលកំពុងប្រើប្រាស់រហូតមកដល់ពេលនេះ នៅក្នុងខេត្ត សិលា ទាំងអស់ គួរពិនិត្យសារឡើងវិញ និងវាយតំលៃក្នុងគោលបំណងចងក្រងជាមេរៀន និងកែតំរូវវិធីសាស្ត្រដែលនឹងត្រូវប្រើនៅក្នុងការចំលងបន្តជាគំរូទៅកាន់ខេត្តថ្មី ។

## ខ . ការត្រួតពិនិត្យ និងវាយតំលៃ

- វិធានការនានា គួរធ្វើឡើងដើម្បីផ្តោតទៅលើប្រព័ន្ធត្រួតពិនិត្យ និងរបាយការណ៍នៃពត៌មាន ដែលត្រូវការសំរាប់គោលបំណងគ្រប់គ្រង ។
- ការសង្កត់បញ្ជាក់ខ្លាំងឡើងថែមទៀត គួរដាក់អោយមាននៅលើការសិក្សាវិភាគ និងការពន្យល់ ខ្លឹមសារនៃទិន្នន័យ និងគុណភាពនៃរបាយការណ៍ ជាជាងផ្តោតការយកចិត្តទុកដាក់ទៅ លើទំហំ និងចំនួនដង ។
- ដោយផ្អែកទៅលើលក្ខណៈបទពិសោធន៍របស់កម្មវិធី ប្រព័ន្ធត្រួតពិនិត្យ គួររាប់បញ្ចូលផងដែរនូវ សមាសភាគដែលរៀបចំឡើង ដើម្បីចងក្រងធ្វើជាឯកសារនៃដំណើរការនៃបទពិសោធន៍ និងការរៀនសូត្រដែលបានឆ្លងកាត់ ។

## ៨. អនុសាសន៍សំរាប់ម្ចាស់ជំនួយ

- គាំទ្រដល់គោលគំនិតរបស់កម្មវិធី សិលា លើការធ្វើផែនការ និងការអភិវឌ្ឍន៍តាមបែបវិមជ្ឈការក្នុងដំណាក់ការបន្ទាប់នៃកម្មវិធី ។
- គាំទ្រដល់ការសហការគ្នានូវរាល់សកម្មភាពការងារ ដែលមាននៅក្នុងខេត្តដែលមានស្រាប់ និងការចំលងបន្តជាគំរូទៅកាន់ខេត្តថ្មីៗទៀត ។
- ធ្វើអោយប្រាកដថា រាល់មូលនិធិវិនិយោគសំរាប់សកម្មភាពអភិវឌ្ឍន៍ ទទួលបានព្រមគ្នាជាមួយនិងភាពគ្រប់គ្រាន់នៃធនធានសំរាប់ការកសាងសមត្ថភាព ស្របគ្នានិងគោលគំនិតរបស់កម្មវិធី សិលា ។
- គាំទ្រដល់យន្តការបំពេញបន្ថែម ដើម្បីអនុវត្តច្បាប់រដ្ឋបាលឃុំ ក្នុងគោលបំណងដើម្បីកាត់បន្ថយសំពាធធ្ងន់ធ្ងរទៅលើកម្មវិធី សិលា ក្នុងការពង្រីកកម្មវិធី សិលាមុនពេលកំណត់ ។
- ផ្តល់ថវិកាដល់មន្ទីរជំនាញខេត្ត ដែលអាចភាពបត់បែនបានគ្រប់គ្រាន់ ដើម្បីអោយបណ្តាមន្ទីរជំនាញ ទាំងនោះអាចបង្កើតកម្មវិធី និងគំរោងរបស់ពួកគេដោយផ្ទាល់ អោយស្របទៅតាមគោលបំណង នៃសហវិមជ្ឈការ ។
- អ្នកពាក់ពន្ធ័និងការអភិវឌ្ឍន៍ទាំងអស់ គួរធ្វើការងារទាំងអស់រួមគ្នាដើម្បីធ្វើអោយប្រាកដថា ដំណើរការបង្កើត និងដំណើរការគៀងគរធនធានមកប្រើប្រាស់បានទាន់ពេលវេលា ដែលអាចនឹងជៀសវាង ការរំខាន និងបាត់បង់ធនធានសំខាន់ៗ ។ ជាការសំខាន់ណាស់ដែលថា ធនធានមនុស្ស បទពិសោធន៍ ដែលមានតំលៃ និងសក្តានុពលភាពដែលបានបង្កើតឡើង មិនត្រូវបានបាត់បង់ដោយសារភាពយឺតយ៉ាវ ក្នុងការបង្កើតកម្មវិធី និងដំណើរការគៀងគរធនធានមកប្រើប្រាស់ឡើយ ។
- រាល់ការខិតខំប្រឹងប្រែងទាំងឡាយ គួរធ្វើឡើងដោយម្ចាស់ជំនួយ ដើម្បីធ្វើអោយប្រាកដនូវចរន្តបង្ហូរធនធានបានទាន់ពេលវេលាទៅអោយកម្មវិធីនាពេលអនាគត ។ ការយឺតយ៉ាវនៅក្នុងការផ្តល់ ដែលបានគ្រងទុកធនធានពីខាងក្រៅ ជាញឹកញយធ្វើអោយមានការព្រួយបារម្ភនៅក្នុងមូលដ្ឋាន ដោយសារភាពគំរិតកំណត់នូវទំហំនៃការអនុវត្តន៍សកម្មភាពការងារតាមរដូវ និងអាចជាឧបសគ្គដល់ដំណើរការកសាងផែនការ និងបំផ្លាញថាមភាព និងកាត់បន្ថយនូវគោលគំនិតនៃភាពជាម្ចាស់ ។

***************